

# អន្តរការីទិន្នន័យបើកចំហ សម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា

## ការសិក្សាសមិទ្ធិលទ្ធភាព និងការពិចារណាសំខាន់ៗ

បណ្ឌិត ប៉ក់ គឹមជឿន

Australian Aid
ពន្លក ចំណេះ
The Asia Foundation

# អន្តរការីទិន្នន័យបើកចំហ
# សម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា

ការសិក្សាសមិទ្ធិលទ្ធភាព និងការពិចារណាសំខាន់ៗ

Australian Aid

ពន្លក ចំណេះ

The Asia Foundation

## អំណរអំណរគុណ

ការសិក្សានេះ ទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈ "កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា" របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលលើកឡើងក្នុងការសិក្សានេះ គឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ីឡើយ។

©អង្គការមូលនិធិអាស៊ី ២០២៣

# មាតិកា


**បញ្ជីប្រអប់ រូបភាព តារាង** ៤

**សេចក្តីសង្ខេប** ៦

**១.សេចក្តីផ្តើម** ៨

១.១ សាវតារ និងសនិទានភាព ៨

១.២ គោលបំណង និងសំណួរក្នុងការស្រាវជ្រាវ ៩

១.៣ វិធីសាស្រ្ត ១០

**២.ទស្សនាទានពាក់ព័ន្ធ និងបទពិសោធន៍ពីប្រទេសផ្សេងទៀត** ១២

**៣.ទិដ្ឋភាពរួមនៃគោលនយោបាយសាធារណៈនិងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា** ២០

**៤.សនិទានភាព និងសមិទ្ធិលទ្ធភាព** ២៤

៤.១ សនិទានភាព ២៤

៤.២ សមិទ្ធិលទ្ធភាព ២៧

**៥.អនុសាសន៍សម្រាប់ជំហានបន្ទាប់** ៣០

៥.១ ការពិចារណាជាយុទ្ធសាស្រ្ត ៣០

៥.២ អនុសាសន៍សម្រាប់អន្តរការីទិន្នន័យបើកចំហ ៣៣

**ឯកសារយោង** ៣៨

# បញ្ជីប្រអប់ រូបភាព និងតារាង

ប្រអប់ទី១៖ គោលការណ៍សម្រាប់ទិន្នន័យបើកចំហ និងគ្រោងការណ៍ដាក់ឱ្យប្រើប្រាស់ទិន្នន័យកម្រិតផ្កាយ៥ ១៤

រូបភាពទី១៖ ក្របខ័ណ្ឌស្ថាប័នសម្រាប់ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា ២១
រូបភាពទី២៖ ការវិភាគ SWOT សម្រាប់សមិទ្ធិលទ្ធភាពនៃអន្តរការីទិន្នន័យបើកចំហ ២៨

តារាងទី១៖ បញ្ហាដែលអាចធ្វើឱ្យរាំងស្ទះដល់ការចែករំលែក និងប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព ១៦
តារាងទី២៖ ការប៉ាន់ប្រមាណហានិភ័យនៅពេលចែករំលែកទិន្នន័យ ១៨
តារាងទី៣៖ ចំណុចសំខាន់ៗនៃសេចក្តីព្រាងយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ ២២
តារាងទី៤៖ ចំណុចយុទ្ធសាស្ត្រដែលតួអង្គនីមួយៗត្រូវផ្តោតសំខាន់ ៣២
តារាងទី៥៖ អនុសាសន៍មួយចំនួនសម្រាប់អ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យបើកចំហ ៣៣

# ពាក្យកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| **CamDX** | ថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា |
| **CDEI** | វិទ្យាស្ថានអភិវឌ្ឍន៍កម្ពុជា |
| **CSOs** | អង្គការសង្គមស៊ីវិល |
| **CSV** | តម្លៃដែលកាត់ដោយក្បៀស |
| **EU** | សហភាពអឺរ៉ុប |
| **FGDs** | កិច្ចពិភាក្សាក្រុមគោលដៅ |
| **IDB** | ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក |
| **M&E** | ការពិនិត្យតាមដាន និងវាយតម្លៃ |
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MOI** | ក្រសួងមហាផ្ទៃ |
| **MOP** | ក្រសួងផែនការ |
| **MOU** | អនុស្សារណៈយោគយល់គ្នា |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល |
| **NIS** | វិទ្យាស្ថានជាតិស្ថិតិ |
| **NSDS** | យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ |
| **NSS** | ប្រព័ន្ធស្ថិតិជាតិ |
| **ODI** | វិទ្យាស្ថានទិន្នន័យបើកចំហ |
| **OECD** | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SWOT** | ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង |
| **The Foundation** | អង្គការមូលនិធិអាស៊ី |
| **UK** | ចក្រភពអង់គ្លេស |
| **UNDESA** | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ |
| **URIs** | ព័ត៌មានសម្គាល់អត្តសញ្ញាណធនធាន |
| **WDR** | របាយការណ៍អភិវឌ្ឍន៍ពិភពលោក |

## សេចក្តីសង្ខេប

នៅពេលដែលកម្ពុជាកាន់តែមានការអភិវឌ្ឍខ្លាំងឡើងអន្តរាគមន៍គោលនយោបាយដែលមានប្រសិទ្ធភាពត្រូវផ្អែកលើទិន្នន័យដែលអាចជឿជាក់បាន។ការលើកកម្ពស់ទិន្នន័យបើកចំហរបស់រដ្ឋាភិបាល ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់អភិបាលកិច្ចទិន្នន័យសម្រាប់គោលបំណងគោលនយោបាយ។ទិន្នន័យបើកចំហនឹងជួយបង្កើនតម្លាភាពក្នុងរដ្ឋាភិបាល ក៏ដូចជាជំរុញឱ្យតួអង្គមិនមែនរដ្ឋចូលរួមផ្តល់យោបល់ត្រឡប់និងរក្សាការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ នៅកម្ពុជា លទ្ធភាពទទួលបាន និងប្រើប្រាស់ទិន្នន័យដោយតួអង្គមិនមែនរដ្ឋសម្រាប់គោលបំណងគោលនយោបាយ គឺនៅមានកម្រិត។ ដំណោះស្រាយមួយដែលត្រូវបានគូសបញ្ជាក់ក្នុងឧទាហរណ៍នៅតាមបណ្តាប្រទេសនានាសម្រាប់ការលើកកម្ពស់ការចែករំលែក និងប្រើប្រាស់ទិន្នន័យ គឺការបង្កើតឱ្យមានអន្តរការីទិន្នន័យ។

ការសិក្សានេះ មានគោលបំណងប៉ាន់ប្រមាណសមិទ្ធិលទ្ធភាពនៃការបង្កើតអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា និងផ្តល់ការពិចារណាជាយុទ្ធសាស្ត្រសំខាន់ៗ។ ការសិក្សានេះផ្អែកលើការសិក្សាស្តីពីគោលនយោបាយសាធារណៈ និងវិស័យស្រាវជ្រាវនៅកម្ពុជាដែលបានធ្វើឡើងនាពេលថ្មីៗនេះ។ ក្រៅពីនេះ មានការអានឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀត និងការធ្វើបទសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅជាមួយអ្នកជំនាញអន្តរជាតិ អ្នកតាក់តែងគោលនយោបាយសំខាន់ៗ អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវវ័យក្មេង និងនិស្សិតសាកលវិទ្យាល័យ។ ទន្ទឹមនឹងនេះ ក៏មានការរៀបចំសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលរកឃើញបឋមពីការសិក្សានេះផងដែរ។

អន្តរការីទិន្នន័យបើកចំហសំដៅលើភ្នាក់ងារមួយដែល ១) ស្ថិតនៅផ្នែកណាមួយនៃសង្វាក់ផ្គត់ផ្គង់ទិន្នន័យដែលរួមបញ្ចូលសំណុំទិន្នន័យបើកចំហ ២) ស្ថិតនៅចន្លោះភ្នាក់ងារ ពីរក្នុងសង្វាក់ផ្គត់ផ្គង់ទិន្នន័យនិង ៣) សម្របសម្រួលការប្រើប្រាស់ទិន្នន័យបើកចំហដែលអាចមិនមានលក្ខណៈបើកចំហ។ អ្វីដែលសំខាន់គឺអ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យបើកចំហត្រូវកំណត់ និងបញ្ជាក់ពីតួនាទីរបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងរបៀបដែលអន្តការីទាំងនោះអាចជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការចែករំលែក និងប្រើប្រាស់ទិន្នន័យ។

បទពិសោធន៍ក្នុងប្រទេសផ្សេងទៀត និងក្នុងប្រទេសកម្ពុជា បានរំលេចបញ្ហាប្រឈមស្រដៀងៗគ្នាពាក់ព័ន្ធនឹងការចែករំលែក និងប្រើប្រាស់ទិន្នន័យ ដូចជា កង្វះការលើកទឹកចិត្តក្នុងការចែករំលែកទិន្នន័យ (ទាំងពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងក្រមសីលធម៌) ហានិភ័យដែលពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ និងចំណាយលើការផ្តល់លទ្ធភាពទទួលបាន និងចែករំលែកទិន្នន័យ។ ហានិភ័យដែលពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ រួមមានហានិភ័យផ្នែកគតិយុត្តិនិងបទបញ្ញត្តិ ហានិភ័យក្រមសីលធម៌ ហានិភ័យកេរ្តិ៍ឈ្មោះ និងហានិភ័យពាណិជ្ជកម្ម។ មានការលើកឡើងពីដំណោះស្រាយផ្សេងៗសម្រាប់ទប់ស្កាត់ និងសម្រាលផលប៉ះពាល់នៃហានិភ័យទាំងនេះ ដូចជា ការធ្វើឱ្យមានភាពអនាមិក ទិន្នន័យសំយោគ ការចែករំលែកទិន្នន័យក្រោមកិច្ចសន្យា ការជំរុញការចូលរួមរបស់ភាគីទីបីឱ្យដើរតួនាទីជាអ្នក

គ្រប់គ្រងទិន្នន័យ ការជំរុញការចូលរួមរបស់សហគមន៍ និងការពិពណ៌នា និងចងក្រងទិន្នន័យទុកជាឯកសារ។

សម្រាប់ករណីរបស់ប្រទេសកម្ពុជា ការសិក្សានេះរកឃើញថា គេអាចបង្កើតឱ្យមានអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជាបាន ដោយសារតែ ១) មានឱកាសជាច្រើនពាក់ព័ន្ធនឹងបរិយាកាសគោលនយោបាយអំណោយផល ២) ផ្នែកដែលអាចចូលរួមចំណែកដោយតួអង្គមិនមែនរដ្ឋ ៣) ឆន្ទៈចូលរួមសហការពីសំណាក់ភាគីពាក់ព័ន្ធផ្សេងៗ ៤) សមត្ថភាពដែលមានស្រាប់ (ទោះបីជាមានកម្រិតខ្លះក៏ដោយ) និង ៥) អត្ថប្រយោជន៍ចំពោះមុខជាច្រើនដែលអាចកំណត់យកជាចំណុចផ្តោតសំខាន់ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម។ ទោះជាយ៉ាងណាការសិក្សាសមិទ្ធិលទ្ធភាពនេះក៏អាស្រ័យផងដែរលើរបៀបដែលអន្តរការីទាំងនោះអាច ១) កែខៃចំណុចខ្សោយរបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងធនធានបច្ចេកទេស និងធនធានមនុស្ស ២) កាត់បន្ថយហានិភ័យដែលពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ និង ៣) កសាងទំនុកចិត្តបន្តិចម្តងៗក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ។

ផ្អែកតាមបទសម្ភាសន៍ អន្តរការីទិន្នន័យបើកចំហអាចចែកចេញជា២ ប្រភេទ។ ***ទីមួយ អន្តការីទិន្នន័យបើកចំហដែលផ្តោតសំខាន់លើបញ្ហា*** ពោលគឺស្ថាប័នដែលផ្តោតសំខាន់លើបញ្ហាជាក់លាក់ ដូចជាតម្លាភាពថវិកាសាធារណៈ អភិបាលកិច្ចមូលដ្ឋានកិច្ចគាំពារសង្គម ការអប់រំសុខភាព កសិកម្ម។ល។ ស្ថាប័នដែលគួរចាត់ចូលក្នុងប្រភេទនេះរួមមានអង្គការមិនមែនរដ្ឋាភិបាលធំៗ ដែលខិតខំជួយដល់សមាជិករបស់ខ្លួន និងចូលរួមតស៊ូមតិឱ្យមានការផ្លាស់ប្តូរគោលនយោបាយក្នុងវិស័យអាទិភាពរបស់ខ្លួនៗ ***ទីពីរ ស្ថាប័នដែលផ្តោតសំខាន់លើការស្រាវជ្រាវ ពោលគឺស្ថាប័នសិក្សាស្រាវជ្រាវ*** ស្ថាប័នស្រាវជ្រាវនិងផ្តល់យោបល់ និងសាកលវិទ្យាល័យដែលមិនផ្តោតសំខាន់លើការតស៊ូមតិក្នុងវិស័យជាក់លាក់ ប៉ុន្តែផ្តោតចម្បងលើការលើកកម្ពស់ការស្រាវជ្រាវ និងវិស័យស្រាវជ្រាវជារួម។ អ្នកទទួលផលពីស្ថាប័នទាំងនេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមអ្នកស្រាវជ្រាវប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន។

ដើម្បីកសាងនិងដំណើរការអន្តរការីទិន្នន័យដែលមានប្រសិទ្ធភាពនិងនិរន្តរភាព ចាំបាច់ត្រូវមានការប្តេជ្ញាចិត្ត និងយុទ្ធសាស្ត្ររយៈពេលវែង រួមជាមួយនឹងខ្លឹមសារលម្អិតសំខាន់ៗមួយចំនួន។ មានការរំពឹងថានឹងមានការប្តេជ្ញាចិត្ត និងការរួមចំណែករយៈពេលវែងពីអ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យបើកចំហ ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដ៏ច្រើន (យ៉ាងហោចណាស់ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម) និងទីភ្នាក់ងាររដ្ឋាភិបាលដែលកិច្ចសហការរបស់ពួកគេដើរតួនាទីសំខាន់ក្នុងដំណើរការនេះទាំងមូល។ នៅកម្រិតប្រតិបត្តិការ អន្តការីទិន្នន័យទាំងនោះត្រូវផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការច្បាមយកព័ត៌មានជាមូលដ្ឋាន តាំងពីដំណាក់កាលដំបូង ដំណាក់កាលអនុវត្តន៍ និងដំណាក់កាលធានានិរន្តរភាព និងពង្រីកបន្ថែម។

# ១. សេចក្ដីផ្ដើម

## ១.១ សាវតារ និងសនិទានភាព

***នៅពេលដែលកម្ពុជាកាន់តែមានការអភិវឌ្ឍខ្លាំងឡើងអន្តរាគមន៍គោលនយោបាយដែលមានប្រសិទ្ធភាពត្រូវផ្អែកលើទិន្នន័យដែលអាចជឿជាក់បាន។*** នេះជាការពិតសម្រាប់ករណីប្រទេសកម្ពុជាដែលរាជរដ្ឋាភិបាលកំពុងអនុវត្តផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩និងកំពុងត្រៀមខ្លួនចាកចេញពីស្ថានភាពជាប្រទេសមានប្រាក់ចំណូលទាបនៅឆ្នាំ ២០២៧[1] ។ ដូច្នេះ ទិន្នន័យត្រូវតែមានគ្រប់គ្រាន់ អាចជឿជាក់បាន និងទាន់ពេលវេលា ដើម្បីឱ្យអ្នកតាក់តែងគោលនយោបាយអាចធ្វើការតម្រឹមតម្រង់ចំណុចដៅគោលនយោបាយដែលចាំបាច់។ចំណុចនេះមានសារៈសំខាន់ណាស់សម្រាប់ធានាការប្រើប្រាស់ធនធានសាធារណៈបានល្អប្រសើរក្នុងពេលដែលធនធានទាំងនោះកាន់តែខ្សត់ទៅៗដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចខាងក្រៅ។

ជារឿយៗ ការលើកកម្ពស់ទិន្នន័យបើកចំហរបស់រដ្ឋាភិបាល ត្រូវបានកំណត់ជាតួនាទីរបស់ក្រុមអង្គការតម្លាភាពអន្តរជាតិ ដើម្បីធានាការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរសម្រាប់គោលបំណងគោលនយោបាយសាធារណៈ។ បទពិសោធន៍ពីបណ្ដាប្រទេសនានាគូសបញ្ជាក់ពីអត្ថប្រយោជន៍មួយចំនួននៃទិន្នន័យបើកចំហរបស់រដ្ឋាភិបាល ដូចជា ការទ្រទ្រង់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ ការបង្កើនប្រសិទ្ធភាព ប្រសិទ្ធផល និងភាពគ្រប់ដណ្ដប់នៃសេវាសាធារណៈ ការបង្កើនតម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ និងការសម្របសម្រួលការចែករំលែកព័ត៌មានកាន់តែល្អប្រសើរក្នុងជួររដ្ឋាភិបាល[2] ។ ដើម្បីសម្រេចបានអត្ថប្រយោជន៍ទាំងនេះ គួរចាត់ទុកទិន្នន័យបើកចំហរបស់រដ្ឋាភិបាលជាប្រព័ន្ធអេកូឡូស៊ីមួយដែលមានទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ហើយផ្នែកទាំងពីរនេះពង្រឹងឱ្យគ្នាទៅវិញទៅមក[3] ។

***ទិន្នន័យដែលត្រូវការចាំបាច់សម្រាប់គោលបំណងគោលនយោបាយមានប្រភពពីប្រព័ន្ធស្ថិតិជាតិដែលចូលរួមដោយតួអង្គផ្សេងៗ។ ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា (ដែលប្រហាក់ប្រហែលគ្នានឹងបណ្តាប្រទេសផ្សេងទៀត)*** រួមមានវិទ្យាស្ថានជាតិស្ថិតិ អង្គភាពស្ថិតិដែលត្រូវបានចាត់តាំងក្រោមឱវាទក្រសួងសាម៉ីផ្សេងៗ និងដៃគូអភិវឌ្ឍន៍ដែលសុទ្ធតែជាអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសំខាន់ៗ។ តួអង្គមិនមែនរដ្ឋគឺអ្នកប្រើប្រាស់ទិន្នន័យ ដូច្នេះ ពួកគេគឺជាធាតុផ្សំដ៏សំខាន់មួយនៃផ្នែកតម្រូវការក្នុងប្រព័ន្ធអេកូឡូស៊ីទិន្នន័យបើកចំហរបស់រដ្ឋាភិបាល។ ក្រុមនេះរួមមានអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ ស្ថាប័នសិក្សា អ្នកស្រាវជ្រាវ និស្សិតសាកលវិទ្យាល័យ ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន។ ជារឿយៗ តួអង្គមិនមែនរដ្ឋទាំងនេះត្រូវបានចាត់ទុកជាអ្នកប្រើប្រាស់ទិន្នន័យ ប៉ុន្តែពួកគេក៏អាចជាអ្នកផលិតទិន្នន័យផងដែរ។

[1] (WTO, 2022) (RGC, 2021)
[2] (UNDESA, 2022)
[3] (IDB, 2018)

***នៅកម្ពុជា លទ្ធភាពទទួលបាន និងប្រើប្រាស់ទិន្នន័យដោយតួអង្គមិនមែនរដ្ឋសម្រាប់គោលបំណងគោលនយោបាយ គឺនៅមានកម្រិត។*** ការអនុវត្តក្នុងបណ្ដាប្រទេសផ្សេងទៀត ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា បានកត់សម្គាល់ថា ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពរបស់ស្ថាប័នសាធារណៈ តួអង្គមិនមែនរដ្ឋត្រូវតែអាចទទួលបាន និងប្រើប្រាស់ទិន្នន័យ។ ទោះជាយ៉ាងណា តួអង្គមិនមែនរដ្ឋនៅកម្ពុជានៅតែប្រឈមនឹងបញ្ហាជាច្រើន រួមមាន ភាពមានកម្រិតនៃធនធានហិរញ្ញវត្ថុធនធានមនុស្សចំណេះដឹង និងលទ្ធភាពក្នុងការទទួលបានទិន្នន័យសាធារណៈ ក៏ដូចជាសមត្ថភាពក្នុងការវិភាគ បកស្រាយ និងផ្សព្វផ្សាយលទ្ធផលរកឃើញសំខាន់ៗ។ ផ្ទុយទៅវិញ រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដែលទោះបីជានៅមានភាពមានកម្រិតជាច្រើនក៏ដោយ ក៏នៅតែមានលទ្ធភាពច្រើនជាងតួអង្គមិនមែនរដ្ឋក្នុងការផលិត ចែករំលែក និងប្រើប្រាស់ទិន្នន័យកាន់តែច្រើនក្នុងរង្វង់ស្ថាប័នរបស់ខ្លួន។

***ដំណោះស្រាយមួយ ដែលត្រូវបានគូសបញ្ជាក់ក្នុងឧទាហរណ៍នៅបណ្ដាប្រទេសនានាសម្រាប់ការលើកកម្ពស់ការចែករំលែក និងប្រើប្រាស់ទិន្នន័យ គឺការបង្កើតឱ្យមានអន្តរការីទិន្នន័យ។*** អន្តរការីទិន្នន័យអាចជួយសម្រួលដល់ការប្រមូល ការផ្ដល់សុពលភាព និងការបូកសរុបទិន្នន័យពីអ្នកចូលរួមផ្ដល់ទិន្នន័យ និងធ្វើឱ្យអ្នកប្រើប្រាស់ទិន្នន័យអាចយល់ ប្រើប្រាស់ និងទទួលបានទិន្នន័យ។ សម្រាប់ទិន្នន័យសាធារណៈ អន្តរការីទិន្នន័យអាចសម្រួលដល់ការចែករំលែកទិន្នន័យប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាពខ្ពស់រវាងស្ថាប័នរដ្ឋាភិបាល ឬរវាងរដ្ឋាភិបាលនិងតួអង្គមិនមែនរដ្ឋ[4] ។ ក្រៅពីនេះ អន្តរការីទិន្នន័យអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែក និងប្រើប្រាស់ទិន្នន័យបើកចំហក្នុងប្រទេសកំពុងអភិវឌ្ឍន៍[5] ។

## ១.២ គោលបំណង និងសំណួរក្នុងការស្រាវជ្រាវ

ការសិក្សានេះ មានគោលបំណងប៉ាន់ប្រមាណសមិទ្ធិលទ្ធភាពនៃការបង្កើតអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា និងផ្ដល់ការពិចារណាជាយុទ្ធសាស្ត្រសំខាន់ៗដោយផ្អែកលើបរិបទ និងសនិទានភាពដែលបានបង្ហាញពីខាងដើម។ លទ្ធផលរកឃើញ និងអនុសាសន៍ដែលបានលើកឡើងគឺសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងស្ថាប័នសិក្សា ដែលចង់បំពេញតួនាទីជាអន្តរការីក្នុងវិស័យ ឬផ្នែករបស់ខ្លួន ក៏ដូចជាសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលកិច្ចសហការ និងការគាំទ្ររបស់ពួកគេមានសារៈសំខាន់សម្រាប់ដំណើរការនៃការរៀបចំអន្តរការីទិន្នន័យ។

[4] ( World Bank, 2021 )
[5] ( Francois, Canares, Chattapadhay, & Andrason, 2016 )

ផ្អែកតាមគោលបំណងនៃការស្រាវជ្រាវ ការសិក្សានេះនឹងឆ្លើយសំណួរ៤ ក្នុងការស្រាវជ្រាវដូចខាងក្រោម ៖

- ផ្អែកតាមឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀត តើអ្វីជាអន្តរការីទិន្នន័យបើកចំហ? តើអន្តរការីទាំងនោះមានតួនាទី និងការរួមចំណែកអ្វីខ្លះដល់ការចែករំលែក និងប្រើប្រាស់ទិន្នន័យឱ្យកាន់តែប្រសើរ? តើត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចយុទ្ធសាស្ត្រសំខាន់ៗអ្វីខ្លះ?
- ផ្អែកតាមករណីរបស់ប្រទេសកម្ពុជា តើមានសនិទានភាពអ្វីខ្លះសម្រាប់ការបង្កើតឱ្យមានអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋ? តើគំនិតនេះរួមទាំងការបង្កើតសមាគមស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ អាចអនុវត្តទៅបានក្នុងកម្រិតណា?
- ប្រសិនបើត្រូវបង្កើតអន្តរការីទិន្នន័យបើកចំហប្រាកដមែន តើភាគីពាក់ព័ន្ធសំខាន់ៗត្រូវផ្តោតការយកចិត្តទុកដាក់លើការពិចារណាជាយុទ្ធសាស្ត្រសំខាន់ៗអ្វីខ្លះ?
- តើអ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យ ត្រូវធ្វើកិច្ចការ និងដោះស្រាយបញ្ហាអ្វីខ្លះ?

## ១.៣ វិធីសាស្ត្រ

***ការសិក្សានេះផ្អែកលើការសិក្សាស្តីពីគោលនយោបាយសាធារណៈ និងវិស័យស្រាវជ្រាវនៅកម្ពុជាដែលបានធ្វើឡើងនាពេលថ្មីៗនេះ*** មានជាអាទិ៍ ការស្រាវជ្រាវដែលធ្វើឡើងដោយកម្មវិធីពន្លកចំណេះ ដូចជា "ការសិក្សាបែបវិភាគស្តីពីដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ៖ ករណីរបស់ប្រទេសកម្ពុជា និងចំណេះដឹងពីអាស៊ាន (២០២២)" និង "យុវជនកម្ពុជា និងវិស័យស្រាវជ្រាវ៖ បញ្ហាប្រឈម ឱកាស និងអនុសាសន៍ (២០២២)" ។ ដូច្នេះក្នុងករណីពាក់ព័ន្ធ ការសិក្សានេះនឹងយោងតាមការសិក្សាខាងលើជាពិសេសសម្រាប់ការវិភាគស្ថានភាពដែលពាក់ព័ន្ធ ក្របខ័ណ្ឌគោលនយោបាយ និងបទពិសោធន៍ក្នុងតំបន់។

ក្រៅពីនេះ មានការអានឯកសារពាក់ព័ន្ធពីបណ្តាប្រទេសផ្សេងទៀត និងការធ្វើបទសម្ភាសន៍ជាមួយអ្នកជំនាញអន្តរជាតិស្តីពីអន្តរការីទិន្នន័យបើកចំហ។ អន្តរការីទិន្នន័យជាទស្សនាទានថ្មីក្នុងបរិបទកម្ពុជា ទោះបីជាខ្លឹមសារពាក់ព័ន្ធក្នុងទស្សនាទាន នេះគឺមិនខុសគ្នាទាំងស្រុងពីអ្វីដែលទីភ្នាក់ងាររដ្ឋាភិបាលសំខាន់ៗ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបាន និងកំពុងអនុវត្តក៏ដោយ។ អ្វីដែលជាចំណុចខុសគ្នា គឺភាគីពាក់ព័ន្ធសំខាន់ៗត្រូវផ្តោតសំខាន់លើការពិចារណាជាប្រព័ន្ធ និងរយៈពេលវែង នៅពេលបង្កើត និងគាំទ្រដល់អន្តរការីទិន្នន័យបើកចំហ។

ទន្ទឹមនឹងនេះ ក៏មានការធ្វើបទសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅជាមួយអ្នកតាក់តែងគោលនយោបាយសំខាន់ៗ អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវយុវវ័យក្មេង និងនិស្សិតសាកលវិទ្យាល័យផងដែរ។ ក្រៅពីការអានឯកសារពាក់ព័ន្ធដោយផ្តោតសំខាន់លើភាពចាំបាច់នៃអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជាក៏មានការប្រមែប្រមូលព័ត៌មានស្តីពីក្តីរំពឹងទុកចំពោះតួនាទី និងអត្ថប្រយោជន៍របស់អន្តរការីទាំងនោះនិងការលើកឡើងពីរបៀបបង្កើត និងគាំទ្រដល់អន្តរការីទាំងនោះ រួមទាំងការពង្រីកតួនាទី និងនិរន្តរភាពរបស់អន្តរការីទាំងនោះផងដែរ។

***បន្ថែមពីនេះ មានការរៀបចំសិក្ខាសាលាផ្ទៀងផ្ទាត់លទ្ធផលរកឃើញបឋមពីការសិក្សានេះ*** ដែលមានអ្នកចូលរួមចំនួន ៨០នាក់ រួមមាន មន្ត្រីដែលធ្វើការឱ្យទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សា និងអ្នកស្រាវជ្រាវយុវវ័យក្មេង។ កិច្ចពិភាក្សា និងយោបល់ត្រឡប់ដែលទទួលបានក្នុងអំឡុងសិក្ខាសាលានេះត្រូវបានប្រើប្រាស់សម្រាប់កែលម្អសេចក្តីព្រាងដំបូង ក្នុងករណីពាក់ព័ន្ធ[6] ។

[6]សិក្ខាសាលានេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២២ នាទីក្រុងភ្នំពេញ។

# ២.

## ទស្សនាទានពាក់ព័ន្ធ និង បទពិសោធន៍ពីប្រទេសផ្សេងទៀត

***ទស្សនាទានសំខាន់ៗមួយចំនួន និងវាក្យស័ព្ទ ត្រូវបានប្រើប្រាស់ជាមគ្គុទេសក៍សម្រាប់ការវិភាគ និងអនុសាសន៍ដែលបានលើកឡើងក្នុងរបាយការណ៍នេះ។*** ទីមួយ គឺនិយមន័យនៃពាក្យ "ទិន្នន័យ" និង "ទិន្នន័យសាធារណៈ"។ ផ្អែកតាមរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០២១ ទិន្នន័យសំដៅលើ "ព័ត៌មានស្ដីពីមនុស្ស វត្ថុ និងប្រព័ន្ធនានា"។ ទិន្នន័យមានទាំងបែបគុណភាព និងបែបបរិមាណ និងអាចរក្សាទុកក្នុងព័ត៌មានទម្រង់ឌីជីថល ឬទម្រង់អាណាឡូក។ ផ្អែកតាមគោលបំណងនៃទិន្នន័យ គេអាចចែកចេញជាទិន្នន័យសម្រាប់គោលបំណងសាធារណៈ ឬទិន្នន័យសម្រាប់គោលបំណងឯកជន (ឧ. សម្រាប់គោលបំណងពាណិជ្ជកម្ម)។ ក្នុងការសិក្សានេះ យើងផ្ដោតសំខាន់លើទិន្នន័យសម្រាប់គោលបំណងសាធារណៈ ឬអាចហៅថា ទិន្នន័យសាធារណៈ[7] ។

***សម្រាប់របាយការណ៍នេះ គួរមានការគូសបញ្ជាក់ពីភាពខុសគ្នារវាងទិន្នន័យសាធារណៈ ទិន្នន័យរដ្ឋាភិបាល*** និងទិន្នន័យបើកចំហរបស់រដ្ឋាភិបាល។ ទិន្នន័យសាធារណៈរួមបញ្ចូលទិន្នន័យទាំងអស់ដែលមានក្នុងវិស័យសាធារណៈ ដូចជា ទិន្នន័យដែលបង្កើតឡើងដោយរដ្ឋាភិបាល ស្ថាប័នសិក្សា សង្គមស៊ីវិល និងវិស័យឯកជន។ ទិន្នន័យរដ្ឋាភិបាលដែលជាសំណុំរងនៃទិន្នន័យសាធារណៈ ត្រូវបាន "កត់ត្រា និងចងក្រងជាឯកសារតាមវិធី និងមធ្យោបាយណាមួយ និងទទួលបាន និងត្រូវបានបង្កើតឡើងក្រោមការបំពេញកិច្ចការសាធារណៈ ដែលកំណត់ដោយច្បាប់ ឬបទបញ្ញត្តិជាធរមាន"។ ទិន្នន័យបើកចំហរបស់រដ្ឋាភិបាលជាទិន្នន័យដែលបើកទូលាយ និងផ្តល់ជូនជាសាធារណៈក្នុងទម្រង់ផ្សេងៗ (រួមទាំងទម្រង់ដែលអាចអានបានដោយប្រព័ន្ធកុំព្យូទ័រ) និងជាធម្មតា ត្រូវបានអនុញ្ញាតឱ្យចូលទាញយក ប្រើប្រាស់ កែសម្រួល និងចែករំលែកដោយសេរី[8] ។

ខណៈដែលអង្គការផ្សេងៗផ្តល់និយមន័យខុសគ្នាតិចតួចនិយមន័យទាំងនោះគឺមួយភាគធំស្រដៀងពាក់ព័ន្ធនឹងចរិតលក្ខណៈសំខាន់ៗនៃទិន្នន័យបើកចំហ។ បើប្រៀបធៀបនិយមន័យនានាដែលកំណត់ដោយអង្គការផ្សេងៗ និងប្រទេសមានប្រាក់ចំណូលខ្ពស់[9] ទិន្នន័យបើកចំហគួរមានលក្ខណៈ ៥ ដូចតទៅ ៖ សេរី ផ្តល់ជូនជាសាធារណៈ អាចប្រើប្រាស់ឡើងវិញបាន មិនមានការរឹតត្បិត និងអាចអានបានដោយប្រព័ន្ធកុំព្យូទ័រ។ ផ្អែកតាមលក្ខណៈ "សេរី" និង "ផ្តល់ជូនជាសាធារណៈ" ទិន្នន័យបើកចំហគួរត្រូវបានផ្តល់ជូនសម្រាប់ការប្រើប្រាស់ជាសាធារណៈ។ "អាចប្រើប្រាស់ឡើងវិញ" មានន័យថា ទិន្នន័យទាំងអស់គួរតែអាចប្រើប្រាស់ឡើងវិញបានទៅតាមវិធីដែលអ្នកប្រើប្រាស់ចង់បាន។

[7] (World Bank, 2021)
[8] (UNDESA, 2020)
[9] ឧទាហរណ៍នៃអង្គការផ្សេងៗ និងប្រទេសជឿនលឿនដែលផ្តល់និយមន័យនៃទិន្នន័យបើកចំហ រួមមានOpen Knowledge Foundation, Open Knowledge international, Open Data Barometer, Gartner, ធនាគារពិភពលោក, អង្គការ OECD, សហភាពអឺរ៉ុប សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស កាណាដា អូស្ត្រាលី និងនូវែលហ្សេឡង់។

‟មិនមានការរឹតត្បិត″ មានន័យថា មនុស្សគ្រប់រូបគួរតែអាចប្រើប្រាស់ទិន្នន័យដោយសេរី ចំណែក ‟អាចអានបានដោយប្រព័ន្ធកុំព្យូទ័រ″ មានន័យថា ទិន្នន័យគួរស្ថិតក្នុងទម្រង់ដែលអាចអាន និង ដំណើរការដោយស្វ័យប្រវត្តិដោយប្រព័ន្ធកុំព្យូទ័រ។ កម្រិតដែលសំណុំទិន្នន័យមួយអាច *អានបានដោយប្រព័ន្ធកុំព្យូទ័រ ជាកត្តាសំខាន់សម្រាប់ការប្រើប្រាស់សំណុំទិន្នន័យនោះ។* ដោយសារតែ មិនមាននិយមន័យលម្អិតសម្រាប់ទិន្នន័យ ‟បើកចំហ″ នៅកម្ពុជា របាយការណ៍នេះនឹងផ្អែកតាម លក្ខណៈទាំង ៥ ខាងលើ នៅពេលពិភាក្សាពីទិន្នន័យបើកចំហរបស់រដ្ឋាភិបាល។ ក្របខ័ណ្ឌ ទស្សនាទានផ្សេងទៀត និងគោលការណ៍នៃទិន្នន័យបើកចំហ ក៏អាចយកជាសំអាងបានផងដែរ (សង្ខេបក្នុងប្រអប់ខាងក្រោម)។

## ប្រអប់ទី១៖ គោលការណ៍សម្រាប់ទិន្នន័យបើកចំហ និង គ្រោងការណ៍ដាក់ឱ្យប្រើប្រាស់ទិន្នន័យកម្រិតផ្កាយ ៥

ប្រសិនបើត្រូវបានផ្តល់ឱ្យប្រើប្រាស់ជាសាធារណៈ ដោយអនុលោមតាមគោលការណ៍ខាងក្រោម គួរចាត់ទុកទិន្នន័យរបស់រដ្ឋាភិបាលជាទិន្នន័យបើកចំហ[10]៖

- **ពេញលេញ៖** ទិន្នន័យសាធារណៈទាំងអស់ត្រូវបានផ្តល់ឱ្យប្រើប្រាស់។ ទិន្នន័យសាធារណៈជាទិន្នន័យដែលមិនស្ថិតក្រោមការរឹតត្បិតដោយឯកជនភាព សន្តិសុខ ឬបុព្វសិទ្ធិ។
- **ចម្បង៖** ទិន្នន័យត្រូវបានផ្តល់ឱ្យប្រើប្រាស់នៅប្រភពផ្ទាល់ ជាមួយនឹងភាពពិស្តារបំផុត និងមិនស្ថិតក្នុងទម្រង់ដុល ឬទម្រង់ដែលត្រូវបានកែប្រែ។
- **ទាន់ពេលវេលា៖** ទិន្នន័យត្រូវបានផ្តល់ឱ្យប្រើប្រាស់យ៉ាងឆាប់រហ័សទៅតាមភាពចាំបាច់ ដើម្បីរក្សាគុណតម្លៃរបស់ទិន្នន័យ។
- **បង្កភាពងាយស្រួល៖** ទិន្នន័យត្រូវបានផ្តល់ជូនសម្រាប់ការប្រើប្រាស់យ៉ាងទូលំទូលាយបំផុត និងសម្រាប់គោលបំណងចម្រុះ។
- **អាចអានបានដោយប្រព័ន្ធកុំព្យូទ័រ៖** ទិន្នន័យត្រូវបានរចនាឡើងយ៉ាងសមស្របសម្រាប់ការដំណើរការដោយស្វ័យប្រវត្តិ។
- **មិនមានការរើសអើង៖** ទិន្នន័យត្រូវបានផ្តល់ជូនសម្រាប់ការប្រើប្រាស់ដោយមនុស្សគ្រប់រូបដោយមិនតម្រូវឱ្យមានការចុះឈ្មោះ។
- **មិនមែនជាកម្មសិទ្ធិផ្តាច់មុខ៖** ទិន្នន័យត្រូវបានផ្តល់ឱ្យប្រើប្រាស់ក្នុងទម្រង់ដែលមិនស្ថិតក្រោមការគ្រប់គ្រងផ្តាច់មុខរបស់ស្ថាប័ន/អង្គភាពណាមួយ។
- **មិនស្ថិតក្រោមអាជ្ញាប័ណ្ណ៖** ទិន្នន័យមិនស្ថិតក្រោមសិទ្ធិថតចម្លងប៉ាតង់ម៉ាកពាណិជ្ជនាម ឬនិយ័តកម្មសម្ងាត់ក្នុងពាណិជ្ជកម្ម ប៉ុន្តែអាចមានការរឹតត្បិតសមស្របលើឯកជនភាព សន្តិសុខ និងបុព្វសិទ្ធិ។ មគ្គុទេសក៍ជាជំនួយមួយទៀតសម្រាប់ការចែករំលែកទិន្នន័យបើកចំហគឺ គ្រោងការណ៍ដាក់ឱ្យប្រើប្រាស់ទិន្នន័យកម្រិតផ្កាយ៥ សម្រាប់ទិន្នន័យបើកចំហ ដែលបង្កើតឡើងដោយ Tim Berners-Lee ដែលជាអ្នកបង្កើត the Web និងជាអ្នកផ្តួចផ្តើម Linked Data។ ខាងក្រោមនេះជាអត្ថន័យនៃផ្កាយនីមួយៗសម្រាប់ទិន្នន័យបើកចំហ [11] ៖

| | |
|---|---|
| ✶ | ធ្វើឱ្យគេអាចរកបានទិន្នន័យរបស់អ្នកក្នុងគេហទំព័រ (ទោះក្នុងទម្រង់អ្វីក៏ដោយ) ក្រោមអាជ្ញាប័ណ្ណបើកទូលាយ |
| ✶✶ | ផ្តល់ជូនសម្រាប់ការប្រើប្រាស់ក្នុងទម្រង់ជាទិន្នន័យដែលមានរចនាសម្ព័ន្ធ (ឧ. ទម្រង់ Excel ជំនួសឱ្យរូបភាពស្កែនរបស់តារាង) |
| ✶✶✶ | ផ្តល់ជូនសម្រាប់ការប្រើប្រាស់ក្នុងទម្រង់បើកចំហដែលមិនមែនជាកម្មសិទ្ធិផ្តាច់មុខ (ឧ. តម្លៃដែលកាត់ដោយក្បៀស (CSV) ជំនួសឱ្យ Excel) |
| ✶✶✶✶ | ប្រើប្រាស់ព័ត៌មានសម្គាល់អត្តសញ្ញាណធនធាន (URIs) សម្រាប់គូសបញ្ជាក់ពីវត្ថុនានា ដើម្បីឱ្យមនុស្សអាចចង្អុលបង្ហាញទិន្នន័យរបស់អ្នកបាន |
| ✶✶✶✶✶ | ផ្សារភ្ជាប់ទិន្នន័យរបស់អ្នកទៅនឹងទិន្នន័យផ្សេងទៀតដើម្បីផ្តល់បរិបទ |

[10] (OECD, 2013)
[11] https://5stardata.info/en/

***តើអ្វីជាអន្តរការីទិន្នន័យបើកចំហ?*** យោងតាម Schalkwyk et al (2016) អន្តការីទិន្នន័យបើកចំហជា "ភ្នាក់ងារមួយដែល ១) ស្ថិតនៅផ្នែកណាមួយនៃសង្វាក់ផ្គត់ផ្គង់ទិន្នន័យដែលរួមបញ្ចូលសំណុំទិន្នន័យបើកចំហ ២) ស្ថិតនៅចន្លោះភ្នាក់ងារ២ ក្នុងសង្វាក់ផ្គត់ផ្គង់ទិន្នន័យ និង ៣) សម្របសម្រួលការប្រើប្រាស់ទិន្នន័យបើកចំហ ដែលអាចមិនមានលក្ខណៈបើកចំហ។ Schalkwyk et al (2016) ក៏លើកឡើងផងដែរថា សង្វាក់ផ្គត់ផ្គង់ទិន្នន័យបើកចំហអាចមានអន្តរការីចម្រុះ និងអាចទាមទារឱ្យមានមូលធនក្នុងទម្រង់ចម្រុះ (សង្គម នយោបាយ បច្ចេកទេស និងហិរញ្ញវត្ថុ) ដើម្បីតភ្ជាប់ការផ្គត់ផ្គង់ និងការប្រើប្រាស់ទិន្នន័យបើកចំហ។ ដូច្នេះ ត្រូវចងចាំថា អន្តរការីទិន្នន័យមានអត្ថិភាពទាំងក្នុង "ទិន្នន័យសាធារណៈដែលបើកចំហ" និងក្នុងវិស័យឯកជន ដែលអន្តរការីទាំងនោះដើរតួនាទីផ្សេងៗ ចាប់ពីបរធនបាលកិច្ចទិន្នន័យ កិច្ចសហប្រតិបត្តិការទិន្នន័យ និងអ្នកគ្រប់គ្រងទិន្នន័យ[12]។

***ដើម្បីឱ្យមានប្រសិទ្ធភាព អន្តរការីទិន្នន័យបើកចំហចាំបាច់ត្រូវកំណត់តួនាទី និង "មូលធន" របស់ខ្លួន។*** ប្រព័ន្ធអេកូឡូស៊ីទិន្នន័យបើកចំហរបស់ប្រទេសមួយអាចមានភាពស្មុគស្មាញ ដូច្នេះ អន្តរការីទិន្នន័យត្រូវកំណត់ និងបញ្ជាក់ពីតួនាទីរបស់ខ្លួន កំណត់ "មូលធន" ដែលពួកគេមាន និងត្រូវមាន និងក្រុមអ្នកទទួលផលគោលដៅ។ ការពិចារណាកម្រិតយុទ្ធសាស្ត្រទាំងនេះនឹងកំណត់មុខងារជាក់លាក់ និងអ្នកដែលអាចក្លាយជាដៃគូរបស់អន្តរការីទាំងនោះ[13]។ វិធីមួយទៀតដើម្បីកំណត់តួនាទី និងការរួមចំណែកទាំងនេះ គឺការពិនិត្យមើលថាតើអន្តរការីទិន្នន័យទាំងនោះអាចចូលរួមក្នុងដំណើរការគោលនយោបាយដោយរបៀបណាបញ្ហាប្រឈមដែលពួកគេចង់ដោះស្រាយពាក់ព័ន្ធនឹងការចែករំលែក និងប្រើប្រាស់ទិន្នន័យ ក៏ដូចជាតម្លៃបន្ថែមដែលពួកគេអាចបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ[14]។

***ពាក់ព័ន្ធនឹងការចែករំលែក និងប្រើប្រាស់ទិន្នន័យ (ទាំងទិន្នន័យបើកចំហ និងទិន្នន័យមិនបើកចំហ) មានការកត់សម្គាល់ពីបញ្ហាប្រឈមទូទៅជាច្រើន*** ដូចជា ១) កង្វះគ្រឿងលើកទឹកចិត្តក្នុងការចែករំលែកទិន្នន័យ ២) កង្វះចំណេះដឹង ៣) ហានិភ័យពាណិជ្ជកម្ម ក្រមសីលធម៌ និងកេរ្តិ៍ឈ្មោះ ៤) ហានិភ័យផ្នែកគតិយុត្តិ និងបទបញ្ញត្តិ ៥) ចំណាយលើការផ្តល់លទ្ធភាពទទួលបាន និងចែករំលែកទិន្នន័យ និង ៦) ការខកខានឱកាសក្នុងការប្រើប្រាស់ទិន្នន័យដើម្បីជាប្រយោជន៍សាធារណៈ។ តារាងខាងក្រោមផ្តល់ការពន្យល់សង្ខេបពីបញ្ហាប្រឈមនីមួយៗ បូករួមនឹងតួនាទីរបស់អន្តរការីទិន្នន័យក្នុងការសម្រាលបញ្ហាទាំងនោះ។ គួរកត់សម្គាល់ថា តួនាទីសមស្របរបស់អន្តរការី ពេលវេលា និងរបៀបបំពេញតួនាទីណាមួយខុសគ្នាតាមករណី ពោលគឺអាស្រ័យលើស្ថានភាពជាក់លាក់ ឱកាស និងឧបសគ្គ។

[12] (Janssen Heleen, Singh Jatinder, 2022)
[13] (Francois, Canares, Chattapadhay, & Andrason, 2016)
[14] (The Foundation, 2022)

## តារាងទី ១ ៖ បញ្ហាដែលអាចធ្វើឱ្យរាំងស្ទះដល់ការចែករំលែក និង ប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព[15]

| បញ្ហា | ការពិពណ៌នា | តួនាទីរបស់អន្តរការីទិន្នន័យ |
|---|---|---|
| ***កង្វះគ្រឿងលើកទឹកចិត្តក្នុងការចែករំលែកទិន្នន័យ*** | អ្នកផ្តល់ទិន្នន័យអាចមិនទទួលបានគ្រឿងលើកទឹកចិត្តគ្រប់គ្រាន់ក្នុងការចែករំលែកឬផ្តល់លទ្ធភាពទទួលបានទិន្នន័យរបស់ខ្លួន (ឧ. ដោយសារតែការចែករំលែកទិន្នន័យទាមទារឱ្យពួកគេរ៉ាប់រងចំណាយឬ កិច្ចខិតខំប្រឹងប្រែងដែលពួកគេមិនអាចប៉ះប៉ូវបានវិញពីអត្ថប្រយោជន៍ទាំងនោះ)។ | ដើរតួនាទីជា "អ្នកចូលរួមចំណែក" ដែលស្ថាប័ននីមួយៗអាចចូលទាញយកសំណុំទិន្នន័យធំៗបានប្រសិនបើពួកគេបានចូលរួមផ្តល់ទិន្នន័យវិញដែរ |
| ***កង្វះចំណេះដឹង*** | អ្នកផ្តល់ទិន្នន័យអាចមិនមានចំណេះដឹងគ្រប់គ្រាន់ស្តីពីសក្តានុពលនៃការប្រើប្រាស់ទិន្នន័យរបស់ខ្លួនខណៈដែលអ្នកប្រើប្រាស់ទិន្នន័យមិនសូវមានចំណេះដឹងស្តីពីប្រភេទទិន្នន័យដែលអាចផ្តល់ឱ្យប្រើប្រាស់និងដោយរបៀបណា។ | ផ្តល់ភាពងាយស្រួលដល់ការរកឃើញសំណុំទិន្នន័យ ដោយជួយឱ្យអ្នកផ្តល់ទិន្នន័យបង្កើតគុណតម្លៃចេញពីទិន្នន័យរបស់ពួកគេ និងជួយឱ្យអ្នកប្រើប្រាស់ទិន្នន័យកំណត់រកកម្មវិធី (app) ដែលមានសក្តានុពល |
| ***ហានិភ័យពាណិជ្ជកម្ម ហានិភ័យក្រមសីលធម៌ និងហានិភ័យកេរ្តិ៍ឈ្មោះ*** | ហានិភ័យតាមការយល់ឃើញ ឬហានិភ័យជាក់ស្តែងនៃការបាត់បង់ឧត្តមភាពប្រកួតប្រជែងការប្រឈមនឹងការខូចកេរ្តិ៍ឈ្មោះដោយសារការប្រើប្រាស់ទិន្នន័យដែលរំលោភ "ទំនុកចិត្ត" របស់អ្នកដទៃឬក៏ការជំរុញឱ្យមានការប្រើប្រាស់ទិន្នន័យប្រកបដោយក្រមសីលធម៌អាចរាំងស្ទះលទ្ធភាពទទួលបាននិងចែករំលែកទិន្នន័យ។ | ផ្តល់ការធានាដល់កម្មវត្ថុទិន្នន័យនិងម្ចាស់ទិន្នន័យថា ទិន្នន័យនឹងត្រូវបានទាញយកសម្រាប់តែគោលបំណងដែលកំណត់ដោយបុគ្គល ឬស្ថាប័នដែលមានការទទួលស្គាល់ប៉ុណ្ណោះ |
| ***ហានិភ័យផ្នែកគតិយុត្តិ និងបទបញ្ញត្តិ*** | ហានិភ័យតាមការយល់ឃើញ ឬហានិភ័យជាក់ស្តែងនៃការរំលោភការការពារទិន្នន័យ សិទ្ធិកម្មសិទ្ធិបញ្ញា ឬលក្ខខណ្ឌបទបញ្ញត្តិអាចរាំងស្ទះដល់ការចែករំលែកទិន្នន័យ។ | ផ្តល់ជំនាញផ្នែកច្បាប់ និងស្តង់ដារទិន្នន័យទូទៅដើម្បីសម្រួលដល់ការចែករំលែកទិន្នន័យដែលអនុលោមតាមការកំណត់ដោយច្បាប់ |

[15] (CDEI, 2021)

| | | |
|---|---|---|
| ***ចំណាយលើការផ្តល់លទ្ធភាពទទួលបាន និងចែករំលែកទិន្នន័យ*** | ចំណាយអាចច្រើនពេក ដោយសារតែកង្វះមូលនិធិ ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា ដែលត្រូវការចាំបាច់ដើម្បីឱ្យការចែករំលែកទិន្នន័យមានប្រសិទ្ធភាពចំណាយ។ | ផ្តល់បរិយាកាសនៃការចែករំលែកទិន្នន័យដែលប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ដូចជា ការអនុវត្តបច្ចេកវិទ្យាដែលពង្រឹងឯកជនភាព |
| ***ការខកខានឱកាសក្នុងការប្រើប្រាស់ទិន្នន័យដើម្បីជាប្រយោជន៍សាធារណៈ*** | ជាករណីដែលការចែករំលែកទិន្នន័យអាចនាំទៅរកអត្ថប្រយោជន៍សេដ្ឋកិច្ច និងសង្គម។ | ផ្តល់លទ្ធភាពជាប់លាប់ក្នុងការទទួលបានទិន្នន័យសើបប្រកបដោយទំនុកចិត្តសម្រាប់គោលបំណងនៃការស្រាវជ្រាវដែលបម្រើឱ្យប្រយោជន៍សាធារណៈ |

***ហានិភ័យ និងកង្វះទំនុកចិត្ត ស្ថិតក្នុងចំណោមកត្តាធំៗដែលរាំងស្ទះការចែករំលែក និងប្រើប្រាស់ទិន្នន័យ។*** ក្នុងចំណោមបញ្ហាប្រឈមដែលមានរៀបរាប់ខាងលើ បញ្ហាដែលងាយនឹងបង្កើតជាការមិនទុកចិត្ត និងបន្ទុចបង្អាក់ការចែករំលែកទិន្នន័យ គឺការមិនសូវគិតគូរពីហានិភ័យក្នុងពេលចែករំលែកទិន្នន័យ។ ថ្មីៗនេះ របាយការណ៍មួយរបស់វិទ្យាស្ថានទិន្នន័យបើកចំហ (ODI) លើកឡើងថាចាំបាច់ត្រូវខិតខំកាត់បន្ថយហានិភ័យឱ្យនៅទាបបំផុត នៅពេលចែករំលែកទិន្នន័យ។ ហានិភ័យមានដូចជា ១) ហានិភ័យផ្នែកគតិយុត្តិ និងបទបញ្ញត្តិ ២) ហានិភ័យក្រមសីលធម៌ ៣) ហានិភ័យកេរ្តិ៍ឈ្មោះ និង ៤) ហានិភ័យពាណិជ្ជកម្ម។

ក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនេះ (សូមមើលតារាងខាងក្រោម) មានសំណួរមគ្គុទេសក៍សរុប ១៣ សំណួរ។ របាយការណ៍នេះក៏បានផ្តល់ដំណោះស្រាយមួយចំនួនផងដែរ រួមមាន ១) ការធ្វើឱ្យមានភាពអនាមិក ២) ទិន្នន័យសំយោគ ៣) ការចែករំលែកទិន្នន័យក្រោមកិច្ចសន្យា ៤) ការជំរុញការចូលរួមរបស់ភាគីទីបីឱ្យដើរតួនាទីជាអ្នកគ្រប់គ្រងទិន្នន័យ ៥) ការជំរុញការចូលរួមរបស់សហគមន៍ និង ៦) ការពិពណ៌នា និងការចងក្រងទិន្នន័យទុកជាឯកសារ (ឧ. ការប្រើប្រាស់ការចងក្រងឯកសារ និងកាតាឡុកសម្រាប់ metadata)[16]។

[16] (ODI, 2022)

## តារាងទី២៖ ការប៉ាន់ប្រមាណហានិភ័យនៅពេលចែករំលែកទិន្នន័យ [17]

| ប្រភេទហានិភ័យ | ការពិពណ៌នា និងសំណួរក្នុងការប៉ាន់ប្រមាណ |
|---|---|
| ***គតិយុត្តិ និងបទបញ្ញត្តិ*** | ហានិភ័យតាមការយល់ឃើញ ឬហានិភ័យជាក់ស្តែងនៃការរំលោភច្បាប់ស្តីពីការការពារទិន្នន័យ សិទ្ធិកម្មសិទ្ធិបញ្ញា លក្ខខណ្ឌបទបញ្ញត្តិផ្សេងទៀត ឬកិច្ចសន្យាផ្លូវច្បាប់។<br>- តើទិន្នន័យនោះមានទិន្នន័យបុគ្គលឬទេ ?<br>- តើទិន្នន័យនោះមានទិន្នន័យតតីយជនឬទេ ?<br>- តើអ្នកទទួលបានការអនុញ្ញាតផ្លូវច្បាប់សម្រាប់ការចែករំលែកទិន្នន័យនោះឬទេ ?<br>- តើមានការពិចារណាផ្លូវច្បាប់ផ្សេងទៀតឬទេ ? |
| ***ក្រមសីលធម៌*** | ហានិភ័យតាមការយល់ឃើញ ឬហានិភ័យជាក់ស្តែងនៃការជំរុញឱ្យមានការប្រមូល ឬប្រើប្រាស់ទិន្នន័យដែលប្រាសចាកក្រមសីលធម៌ ឬការបង្កផលប៉ះពាល់ដោយផ្ទាល់លើប្រជាជន និងសហគមន៍។<br>- តើមានពាក់ព័ន្ធនឹងការពិចារណាផ្នែកវប្បធម៌ ឬទេ ?<br>- តើការចែករំលែកទិន្នន័យនោះ អាចបង្កផលប៉ះពាល់លើប្រជាជន ឬសហគមន៍ឬទេ ?<br>- តើការចែករំលែកទិន្នន័យនោះនឹងបង្កផលប៉ះពាល់លើបរិស្ថានធម្មជាតិឬទេ ?<br>- តើទិន្នន័យនោះមានខ្លឹមសារដែលអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិឬទេ ?<br>- តើទិន្នន័យនោះមានខ្លឹមសារ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរបស់អង្គការ ឬបុគ្គលិកអង្គការនោះឬទេ ? |
| ***កេរ្តិ៍ឈ្មោះ*** | ហានិភ័យតាមការយល់ឃើញ ឬហានិភ័យជាក់ស្តែងនៃការខូចកេរ្តិ៍ឈ្មោះ ដែលបណ្តាលមកពីការចែករំលែក ឬប្រើប្រាស់ទិន្នន័យដែលរំលោភទំនុកចិត្ត ឬបង្ហាញពីព្រំដែនកំណត់ក្នុងដំណើរការ ឬការវិភាគនានា។<br>- តើមាននរណាម្នាក់ភ្ញាក់ផ្អើលនៅពេលអ្នកគ្រប់គ្រងចែករំលែកឬប្រើប្រាស់ទិន្នន័យទាំងនេះឬទេ ?<br>- តើត្រូវមានការក្រើនរំលឹកលើគុណភាពទិន្នន័យឬទេ ?<br>- តើក្នុងសំណុំទិន្នន័យនោះមានផ្នែកដែលមិនមានអត្ថបទឬផ្នែកសម្រាប់បញ្ចេញមតិឬទេ ? |
| ***ពាណិជ្ជកម្ម*** | ហានិភ័យតាមការយល់ឃើញ ឬហានិភ័យជាក់ស្តែងនៃការបាត់បង់ភាពប្រកួតប្រជែងក្នុងទីផ្សារ។<br>- តើទិន្នន័យនោះមានខ្លឹមសារដែលអាចធ្វើឱ្យប៉ះពាល់ដល់ពាណិជ្ជកម្មឬទេ ? |

[17] ( ODI, 2022 )

***ថ្នាលឌីជីថលជាគន្លឹះសម្រាប់ការចែករំលែកទិន្នន័យប្រកបដោយប្រសិទ្ធភាពក្នុងយុគសម័យឌីជីថលនេះ។*** ជាមួយនឹងការមកដល់នៃបច្ចេកវិទ្យាឌីជីថល វិធីដែលមានប្រសិទ្ធភាពសម្រាប់ការចែករំលែកទិន្នន័យ គឺតាមរយៈប្រព័ន្ធអ៊ីនធឺណិត។ ដូច្នេះកម្រិតនៃឌីជីថលរូបនីយកម្ម(ទាំងក្នុងផ្នែករដ្ឋាភិបាល និងផ្នែកមិនមែនរដ្ឋាភិបាល) ត្រូវបានចាត់ទុកជាផ្នែកសំខាន់មួយក្នុងប្រព័ន្ធអេកូឡូស៊ីនៃទិន្នន័យបើកចំហរបស់រដ្ឋាភិបាល[18] ។

[18] (UNDESA, 2022)

# ៣. ទិដ្ឋភាពរួមនៃគោលនយោបាយសាធារណៈ និងការប្រើប្រាស់ទិន្នន័យនៅកម្ពុជា

***ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ដំណើរការគោលនយោបាយនៅកម្ពុជាមានភាពប្រសើរឡើង ប៉ុន្តែនៅតែមានបញ្ហាប្រឈមមួយចំនួន។*** ដំណើរការគោលនយោបាយ ចាប់ពីការតាក់តែង ការអនុវត្ត រហូតដល់ការពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានរំលេចក្នុងរបាយការណ៍ថ្មីមួយរបស់អង្គការមូលនិធិអាស៊ីដែលមានចំណងជើងថា"ការសិក្សាបែបវិភាគស្តីពីដំណើរការគោលនយោបាយ និងការប្រើប្រាស់ទិន្នន័យ"[19]។ គួរកត់សម្គាល់ថា ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ មានការបង្កើត និងកែលម្អដំណើរការគោលនយោបាយដែលមានស្តង់ដារជាបន្តបន្ទាប់ និងមានការប្រើប្រាស់ទិន្នន័យកាន់តែច្រើនឡើង។ ទោះជាយ៉ាងណា ភាពពាក់ព័ន្ធគ្នារវាងគោលនយោបាយ និងថវិកា និងការពិនិត្យតាមដាន និងវាយតម្លៃ គឺនៅមានកម្រិតនៅឡើយ (ជាពិសេសនៅកម្រិតផលប៉ះពាល់)។ កត្តាជាក់ស្តែងផ្សេងទៀតដែលជះឥទ្ធិពលលើគុណភាពនៃដំណើរការគោលនយោបាយរួមមានចំណាប់អារម្មណ៍ផ្នែកនយោបាយ ការសម្របសម្រួលឆ្លងក្រសួង និងកត្តាមនុស្ស (ឧ. ការដឹកនាំ អ្នកជំនាញវ័យក្មេង ទំនុកចិត្ត)[20] ។

***នៅកម្ពុជា អភិបាលកិច្ចទិន្នន័យប្រកបដោយប្រសិទ្ធភាពត្រូវបានកត់សម្គាល់ជាកត្តាសំខាន់ដែលផ្តល់មូលដ្ឋានព័ត៌មានដល់ដំណើរការគោលនយោបាយ។*** មិនខុសពីបណ្តាប្រទេសផ្សេងទៀតនោះទេ រដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍គឺជាអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យចម្បងជាងគេ។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ភាគីពាក់ព័ន្ធសំខាន់ៗបានផលិតទិន្នន័យយ៉ាងច្រើននៅក្នុងប្រព័ន្ធស្ថិតិជាតិ ដូចជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសាម៉ី និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ រដ្ឋាភិបាលបានលើកទឹកចិត្តឱ្យមានការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរ តាមរយៈយុទ្ធសាស្ត្រកំណែទម្រង់ផ្សេងៗ ដូចជា យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥)។ ទន្ទឹមនឹងនេះ មានការបង្កើតភាពជាដៃគូនៅកម្រិតអាស៊ាន ដើម្បីបន្តកែលម្អប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហការក្នុងតំបន់លើផ្នែកទិន្នន័យ រួមទាំង Big Data។

[19] (The Foundation, 2022)
[20] (The Foundation, 2022)

## រូបភាពទី១៖ ក្របខ័ណ្ឌស្ថាប័នសម្រាប់ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា [21]




វិទ្យាស្ថានជាតិស្ថិតិដើរតួនាទីប្រៀបដូចជា “អន្តរការីទិន្នន័យ” សម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល ប៉ុន្តែវិទ្យាស្ថាននេះប្រឈមនឹងភាពមានកម្រិតនៃការយល់ដឹង និងសមត្ថភាព។ យោងតាមច្បាប់ស្តីពីស្ថិតិ (២០១៥) និងអនុក្រឹត្យចំនួន ២ ដែលកំណត់ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា[22] វិទ្យាស្ថានជាតិស្ថិតិដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលការគ្រប់គ្រងទិន្នន័យរបស់រដ្ឋាភិបាល ប៉ុន្តែនៅតែមិនសូវមានការយល់ដឹងពីតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងទីភ្នាក់ងារពាក់ព័ន្ធ នៅឡើយ។ រដ្ឋាភិបាលកម្ពុជាបានខិតខំដោះស្រាយបញ្ហាទាំងនេះតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការអនុវត្តយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ ដែលជាឯកសារសំខាន់មួយ ទោះបីជាឯកសារនោះនៅជាសេចក្តីព្រាងក៏ដោយ។ សេចក្តីព្រាងយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ កំណត់ពីគោលបំណង និងគោលការណ៍សំខាន់ៗដែលស៊ីសង្វាក់គ្នានឹងការអនុវត្តល្អបំផុតពាក់ព័ន្ធនឹងទិន្នន័យបើកចំហ (សូមមើលតារាងសង្ខេបខាងក្រោម)។

[21] (RGC, 2018)

[22] អនុក្រឹត្យទាំង ២ នោះរួមមាន ១) អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃប្រព័ន្ធស្ថិតិជាតិ (២០០៧) និង ២) អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង (២០១០)។

## តារាងទី៣៖ ចំណុចសំខាន់ៗនៃសេចក្ដីព្រាងយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ[23]

| គោលបំណងសំខាន់ៗ | គោលការណ៍សំខាន់ៗ | មធ្យោបាយជំរុញការចូលរួម |
| --- | --- | --- |
| • បង្កើតយន្តការផ្ដល់យោបល់ត្រឡប់ដើម្បីបង្កើនការយល់ដឹងរវាងអ្នកប្រើប្រាស់ទិន្នន័យ និងអ្នកផលិតទិន្នន័យ ដើម្បីធានាការផលិតទិន្នន័យ និងស្ថិតិផ្អែកតាមតម្រូវការ<br>• បង្កើនអក្ខរកម្មស្ថិតិសម្រាប់អ្នកប្រើប្រាស់ទិន្នន័យ និងអក្ខរកម្មគោលនយោបាយសម្រាប់អ្នកផលិតទិន្នន័យ<br>• ពង្រឹងយន្តការសម្របសម្រួលដើម្បីបង្កើនការបង្កភាពងាយស្រួល តម្លាភាព និងភាពអាចរកបានទិន្នន័យដែលមានគុណភាព និងអាចជឿជាក់បាន ដើម្បីទ្រទ្រង់ការជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ<br>• កសាងទំនុកចិត្តគ្នាទៅវិញទៅមករវាងអ្នកផលិតទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យដើម្បីពង្រឹងការសហការគ្នា | • បរិយាបន្ន<br>• គណនេយ្យភាព<br>• ភាពអាចជឿទុកចិត្តបាន<br>• ការរក្សាសម្ងាត់<br>• ភាពមានវិជ្ជាជីវៈ<br>• ភាពឆ្លើយតប<br>• សុខុដុមនីយកម្ម<br>• ស្តង់ដារនីយកម្ម<br>• ការបង្កភាពងាយស្រួល<br>• ការកំណត់អាទិភាព<br>• តម្លាភាព/ភាពបើកចំហ<br>• ភាពពាក់ព័ន្ធ | • ការបណ្ដុះបណ្ដាល ការបង្វឹកបង្ហាត់ ការណែនាំ<br>• សិក្ខាសាលាពិគ្រោះយោបល់<br>• ការប៉ាន់ប្រមាណតម្រូវការអ្នកប្រើប្រាស់ទិន្នន័យ<br>• ក្រុមការងារអន្តរក្រសួង<br>• កិច្ចសន្ទនារវាងអ្នកផលិតទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យ<br>• ក្រុមគោលដៅ<br>• ព្រឹត្តិការណ៍លេចធ្លោរ<br>• ព្រឹត្តិប័ត្រព័ត៌មាន សេចក្ដីប្រកាសព័ត៌មាន<br>• ការជំរុញការចូលរួមដោយផ្ទាល់<br>• ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក<br>• កិច្ចព្រមព្រៀងផ្លូវការ |

[23] ( NIS, Upcoming )

***មកទល់បច្ចុប្បន្ន មានការចូលរួមតិចតួចប៉ុណ្ណោះពីសំណាក់តួអង្គមិនមែនរដ្ឋ ដែលជាចម្បងគឺដោយសារបញ្ហាទំនុកចិត្ត។*** ខ្សែបណ្តាញផ្ទាល់ខ្លួន មិត្តភាព និងការយល់ឃើញពីនិន្នាការនយោបាយ នៅតែមានសារៈសំខាន់សម្រាប់ការកសាងទំនុកចិត្តរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ទោះជាយ៉ាងណា តាមការសង្កេតគឺហាក់មានភាពងាយស្រួលជាងក្នុងការកសាងទំនុកចិត្ត និងទំនាក់ទំនងក្នុងចំណោមអ្នកធ្វើការក្នុងការិយាល័យ និងអ្នកជំនាញវ័យក្មេងនៅក្នុងអង្គការសង្គមស៊ីវិល ដែលមួយផ្នែកគឺដោយសារតែពួកគេច្រើនតែមានសាវតារអប់រំ និងវិជ្ជាជីវៈដូចគ្នា (ឧ. រៀនសាលាជាមួយគ្នា ទទួលបានអាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលដូចគ្នា។ល។)។ ការសិក្សាកន្លងមកក៏បានកត់សម្គាល់ពីនិន្នាការវិជ្ជមានមួយចំនួនទៀតផងដែរ។ ទីមួយ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ អ្នកស្រាវជ្រាវកម្ពុជាបានដើរតួនាទីកាន់តែសំខាន់ក្នុងស្ថាប័នសិក្សាស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់។ ទីពីរ មានការបង្កើតក្រុមអ្នកស្រាវជ្រាវវ័យក្មេងកាន់តែច្រើនដែលទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិល។ និន្នាការវិជ្ជមានទាំងនេះបង្ហាញពីសក្តានុពលខ្ពស់សម្រាប់ការកសាងវិស័យស្រាវជ្រាវនៅកម្ពុជា[24] ។

រដ្ឋាភិបាលកម្ពុជា ចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើទិន្នន័យបើកចំហរបស់រដ្ឋា-ភិបាល ក៏ដូចជារដ្ឋាភិបាលឌីជីថល។ ទោះបីជា "ទិន្នន័យបើកចំហរបស់រដ្ឋាភិបាល" គឺជាគោលគំនិតថ្មីស្រឡាងសម្រាប់កម្ពុជាក្តី ប៉ុន្តែគោលនយោបាយនេះត្រូវបានលើកឡើងក្នុងគោលនយោបាយផ្សេងៗរបស់រដ្ឋាភិបាល ជាពិសេសគោលនយោបាយរដ្ឋាភិបាលឌីជីថលដែលត្រូវបានអនុម័តក្នុងឆ្នាំ២០២២។ កម្ពុជាបានបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលគ្រប់គ្រងគណៈកម្មា-ធិការចំនួន ៣ រួមមាន ១) គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ២) គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និង ៣) គណៈកម្មាធិការសន្តិសុខឌីជីថល[25] ។

***យោងតាមគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា មានការគ្រោងធ្វើកំណែទម្រង់ផ្សេងៗដើម្បីកែលម្អអភិបាលកិច្ចទិន្នន័យ ជាពិសេសផ្នែកផ្គត់ផ្គង់។*** ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (២០២១-២០៣៥) និងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) គូសបញ្ជាក់ពីសកម្មភាពកែទម្រង់សំខាន់ៗដើម្បីលើកកម្ពស់ការផលិតទិន្នន័យ ការធានាគុណភាពទិន្នន័យ ការរក្សាទុកទិន្នន័យ និងការចែករំលែកទិន្នន័យទាំងក្នុងរដ្ឋាភិបាល និងជាមួយតួអង្គមិនមែនរដ្ឋ[26]។ ទោះជាយ៉ាងណា មិនទាន់មានការអនុវត្តកំណែទម្រង់ទាំងនេះនៅឡើយទេ។

[24] (The Foundation, 2022)
[25] (RGC, 2022)
[26] (RGC, 2021) (RGC, 2018)

# ៤. សនិទានភាព និង សមិទ្ធិលទ្ធភាព

## ៤.១. សនិទានភាព

ដូចការលើកឡើងពីខាងដើម ដើម្បីឱ្យទិន្នន័យបើកចំហរបស់រដ្ឋាភិបាលមានប្រសិទ្ធភាព ចាំបាច់ត្រូវមានការកែលម្អជាបន្តបន្ទាប់ទាំងលើផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។ ខណៈដែលមានសកម្មភាពកែទម្រង់គួរឱ្យកត់សម្គាល់ក្នុងផ្នែកផ្គត់ផ្គង់ របាយការណ៍នេះផ្តោតសំខាន់លើផ្នែកតម្រូវការ ជាពិសេសផ្នែកតម្រូវការដែលពាក់ព័ន្ធនឹងតួអង្គមិនមែនរដ្ឋ។ ការជំរុញការចូលរួមរបស់តួអង្គមិនមែនរដ្ឋក្នុងប្រព័ន្ធអេកូឡូស៊ីទិន្នន័យទាំងមូល គឺនៅមានកម្រិត ពោលគឺមិនទាន់សកម្មដូចតួអង្គរដ្ឋាភិបាលសំខាន់ៗ នឹងដៃគូអភិវឌ្ឍន៍នោះទេ។ នេះជាសនិទានភាពដែលនាំឱ្យមានការចោទសួរថាតើចាំបាច់ត្រូវមានអន្តរការីទិន្នន័យដើម្បីជួយដល់តួអង្គមិនមែនរដ្ឋឬទេ។

អ្នកផ្តល់ព័ត៌មានសំខាន់ និងអ្នកចូលរួមទាំងអស់ក្នុងការសិក្សានេះ គាំទ្រពេញទំហឹងនូវគំនិតបង្កើតឱ្យមានអន្តរការីទិន្នន័យសម្រាប់តួអង្គមិនមែនរដ្ឋ។ តួអង្គមិនមែនរដ្ឋ មានដូចជា អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ និងសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ (ជាពិសេសអ្នកស្រាវជ្រាវវ័យក្មេង) ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន។ តាមការគូសបញ្ជាក់អ្នកតបសម្ភាសន៍រំពឹងថាអន្តរការីទិន្នន័យនឹងអាចជួយដោះស្រាយបញ្ហា និងបំពេញតម្រូវការជាក់លាក់ ក៏ដូចជាលុបបំបាត់គម្លាតទាំងសម្រាប់ភាគីតួអង្គមិនមែនរដ្ឋ និងភាគីរដ្ឋាភិបាល។

***ភាគីតួអង្គមិនមែនរដ្ឋ នៅតែមានបញ្ហាប្រឈមមួយចំនួន*** ដូចជា ១) លទ្ធភាពមានកម្រិតរបស់អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ និងសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន ក្នុងការទទួលបានទិន្នន័យសាធារណៈដែលត្រូវការចាំបាច់សម្រាប់ការកែលម្អការងាររបស់ពួកគេក្នុងការតស៊ូមតិ ឬគោលបំណងផ្សេងទៀត ២) ការយល់ដឹងមានកម្រិតក្នុងចំណោមតួអង្គមិនមែនរដ្ឋទាំងនេះស្តីពីទិន្នន័យដែលមានស្រាប់ និង ៣) សមត្ថភាពមានកម្រិតក្នុងការបកស្រាយ និងការប៉ាន់ប្រមាណទិន្នន័យ។

***ភាគីរដ្ឋាភិបាលមានឆន្ទៈមុះមុតក្នុងការបង្កើនការចែករំលែក និងប្រើប្រាស់ទិន្នន័យ។*** ចំណុចនេះត្រូវបានកត់សម្គាល់ក្នុងបទសម្ភាសន៍ដែលបានធ្វើឡើង និងត្រូវបានដាក់បញ្ចូលផងដែរក្នុងគោលនយោបាយដែលបានតាក់តែងឡើង ដូចជា យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (២០១៩-២០២៣) និងយុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ[27]។ ដូចការលើកឡើងពីខាងដើម យុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យដែលនៅជាសេចក្តីព្រាងនៅឡើយ បានដាក់បញ្ចូលគោលបំណងមួយដែលស៊ីសង្វាក់គ្នានឹងគំនិត ដែលអន្តរការីទិន្នន័យខិតខំសម្រេចបាន។ គោលបំណងនោះគឺ ៖

- ការបង្កើតយន្តការផ្តល់យោបល់ត្រឡប់ ដើម្បីបង្កើនការយល់ដឹងរវាងអ្នកប្រើប្រាស់ទិន្នន័យ និងអ្នកផលិតទិន្នន័យ ដើម្បីធានាការផលិតទិន្នន័យ និងស្ថិតិដែលផ្អែកតាមតម្រូវការ
- បង្កើនអក្ខរកម្មស្ថិតិសម្រាប់អ្នកប្រើប្រាស់ទិន្នន័យនិងអក្ខរកម្មគោលនយោបាយសម្រាប់អ្នកផលិតទិន្នន័យ
- ពង្រឹងយន្តការសម្របសម្រួលដើម្បីបង្កើនលទ្ធភាពទទួលបាន តម្លាភាព និងភាពអាចរកបានទិន្នន័យដែលមានគុណភាព និងអាចជឿទុកចិត្តបាន ដើម្បីទ្រទ្រង់ការជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ
- កសាងទំនុកចិត្តលើគ្នាទៅវិញទៅមករវាងអ្នកផលិតទិន្នន័យនិងអ្នកប្រើប្រាស់ទិន្នន័យដើម្បីពង្រឹងការសហការគ្នា។

***ក្នុងនាមជាអ្នកប្រើប្រាស់ទិន្នន័យ តួអង្គមិនមែនរដ្ឋមិនសូវមានវឌ្ឍនភាពពាក់ព័ន្ធនឹងលទ្ធភាពទទួលបានទិន្នន័យ ការយល់ដឹង និងសមត្ថភាពក្នុងការប្រើប្រាស់ទិន្នន័យ។*** ផ្អែកតាមការសិក្សាកន្លងមក និងបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ដែលបានធ្វើឡើងសម្រាប់ការសិក្សានេះ មានការបញ្ជាក់ថា រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យក្នុងស្ថាប័នរបស់ខ្លួន ប៉ុន្តែការចែករំលែកទិន្នន័យគឺមិនបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនោះទេ។

***ឧទាហរណ៍ជាក់លាក់នៃវឌ្ឍនភាពដែលសម្រេចបានដោយរដ្ឋាភិបាលកម្ពុជា គឺការប្រើប្រាស់ប្រព័ន្ធ CamDX និង CamStat ក្នុងរដ្ឋាភិបាល*** ប៉ុន្តែនៅតែចាំបាច់ត្រូវមានការកែលម្អលើគុណភាព ការបង្កភាពងាយស្រួល ការយកចិត្តទុកដាក់លើអ្នកប្រើប្រាស់ និងភាពជាប់លាប់នៃការចែករំលែកទិន្នន័យ[28] ។ ទោះជាមានព្រំដែនកំណត់ដូចខាងលើក៏ដោយ ប៉ុន្តែគំនិតផ្តួចផ្តើមទាំងនេះបានបង្ហាញពីវឌ្ឍនភាពដ៏ធំ បើធៀបនឹងភាគីតួអង្គមិនមែនរដ្ឋ។ ឧ. ជាមួយនឹងប្រព័ន្ធ CamDX ការផ្លាស់ប្តូរទិន្នន័យរវាងក្រសួងពាក់ព័ន្ធ (ឧ. ក្នុងការចុះបញ្ជីអាជីវកម្ម) អាចធ្វើឡើងតាមរយៈថ្នាលឌីជីថលដែលមានប្រសិទ្ធភាពជាងមុន និងមិនសូវមានកំហុសដែលបង្កឡើងដោយមនុស្ស។ ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ (ជាពិសេសវិទ្យាស្ថានជាតិ

[27] (RGC, 2018) (NIS,
[28] (The Foundation, 2022)

ស្ថិតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ល។) បានកត់សម្គាល់ព្រំដែនកំណត់ទាំងនេះ និងខិតខំធ្វើឱ្យមានភាពប្រសើរឡើងដោយប្រើប្រាស់មធ្យោបាយផ្សេងៗ។ មធ្យោបាយមួយគឺការជំរុញការចូលរួម និងការទទួលបានយោបល់ត្រឡប់ពីអ្នកប្រើប្រាស់ទិន្នន័យដែលជាតួអង្គមិនមែនរដ្ឋ។

ព្រំដែនកំណត់លើភាគីតួអង្គមិនមែនរដ្ឋ បានធ្វើឱ្យពួកគេខកខានឱកាសជាច្រើនក្នុងការរួមចំណែកដល់ដំណើរការគោលនយោបាយ។ ផ្អែកតាមការសិក្សា និងបទសម្ភាសន៍កន្លងមកទាំងអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាល សុទ្ធតែយល់ស្របថា មានឱកាសកាន់តែច្រើនសម្រាប់ឱ្យតួអង្គមិនមែនរដ្ឋចូលរួម និងផ្តល់ធាតុ ចូលក្នុងដំណើរការគោលនយោបាយ ប៉ុន្តែភាពមានកម្រិតនៃលទ្ធភាពទទួលបានទិន្នន័យ និងសមត្ថភាព ធ្វើឱ្យគេមិនអាចចាប់យកឱកាសទាំងនេះប្រកបដោយប្រសិទ្ធភាពបានឡើយ។

***ព្រំដែនកំណត់ទាំងនេះ ក៏ធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរយៈពេលវែងលើផ្នែកដែលពាក់ព័ន្ធនឹងទិន្នន័យផងដែរ។*** សមត្ថភាពនេះគឺចាំបាច់ទាំងសម្រាប់តួអង្គមិនមែនរដ្ឋ និងសម្រាប់រដ្ឋាភិបាល។ បទសម្ភាសន៍ និងឯកសារគោលនយោបាយគូសបញ្ជាក់ថា ដើម្បីឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល រដ្ឋាភិបាលឌីជីថល និងសង្គមឌីជីថល អ្វីដែលចាំបាច់បំផុតគឺត្រូវធ្វើយ៉ាងណាឱ្យប្រជាជនកាន់តែច្រើនមានទិន្នន័យ និងជំនាញឌីជីថល ប៉ុន្តែបច្ចុប្បន្ន គឺមិនសូវមានធនធានទាំងនេះនោះទេ។ ទោះជាយ៉ាងណា ការសិក្សា និងបទសម្ភាសន៍កន្លងមកលើកឡើងថា មានចំណាប់អារម្មណ៍កាន់តែច្រើនពីសំណាក់ស្ថាប័នសិក្សាស្រាវជ្រាវ សាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវវ័យក្មេងក្នុងការលើកកម្ពស់ និងចូលរួមក្នុងការងារស្រាវជ្រាវ។ អ្វីដែលនៅតែជាកត្តារាំងស្ទះដល់ការសម្រេចបានសក្តានុពលរបស់ភាគីពាក់ព័ន្ធទាំងនេះ គឺភាពមានកម្រិតនៃលទ្ធភាពទទួលបាន ការយល់ដឹង និងសមត្ថភាពដែលពាក់ព័ន្ធនឹងទិន្នន័យ។

***ជារួមនៅតែចាំបាច់ត្រូវមានអន្តរការីទិន្នន័យបើកចំហទាំងសម្រាប់អាទិភាពអភិវឌ្ឍន៍រយៈពេលខ្លី និងអាទិភាពអភិវឌ្ឍន៍រយៈពេលវែងនៅកម្ពុជា។*** អន្តរការីទិន្នន័យបើកចំហអាចដើរតួនាទីជាអ្នកដោះស្រាយបញ្ហាប្រឈម និងលុបបំបាត់គម្លាតក្នុងពេលបច្ចុប្បន្ន រួមចំណែកដល់អាទិភាពរយៈពេលវែងរបស់រដ្ឋាភិបាលដើម្បីធ្វើឱ្យប្រព័ន្ធស្ថិតិជាតិទាំងមូលមានភាពប្រសើរឡើង ក៏ដូចជាជួយកសាងរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថលនៅកម្ពុជា ក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

## ៤.២ សមិទ្ធិលទ្ធភាព

***ការបង្កើតឱ្យមានអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា គឺអាចទៅរួច។*** ផ្អែកតាមឯកសារពាក់ព័ន្ធ និងទស្សនៈយល់ឃើញរបស់អ្នកផ្ដល់ព័ត៌មានសំខាន់ ឯកសារនេះបានបញ្ចូលព័ត៌មានដែលប្រមូលបានទៅក្នុងការវិភាគ SWOT (ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង) ដូចខាងក្រោម៖

- គេអាចបង្កើត និងដំណើរការអន្តរការីទិន្នន័យបើកចំហសម្រាប់តួអង្គមិនមែនរដ្ឋនៅកម្ពុជា ដោយសារតែ ១) មានឱកាសជាច្រើនពាក់ព័ន្ធនឹងបរិយាកាសគោលនយោបាយអំណោយផល ២) ផ្នែកដែលអាចចូលរួមចំណែកដោយតួអង្គមិនមែនរដ្ឋ ៣) ធន្ទៈចូលរួមសហការពីសំណាក់ភាគីពាក់ព័ន្ធផ្សេងៗ ៤) សមត្ថភាពដែលមានស្រាប់ (ទោះបីជាមានកម្រិតខ្លះក៏ដោយ) និង ៥) អត្ថប្រយោជន៍ចំពោះមុខជាច្រើនដែលអាចកំណត់យកជាចំណុចផ្ដោតសំខាន់ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម។
- ទោះជាយ៉ាងណា ការសិក្សាសមិទ្ធិលទ្ធភាពនេះក៏អាស្រ័យផងដែរលើរបៀបដែលអន្តរការីទាំងនោះអាច ១) កែខៃចំណុចខ្សោយរបស់ខ្លួន ជាពិសេសពាក់ព័ន្ធនឹងធនធានបច្ចេកទេស និងធនធានមនុស្ស ២) កាត់បន្ថយហានិភ័យដែលពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ និង ៣) កសាងទំនុកចិត្តបន្តិចម្ដងៗក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ។

### រូបភាពទី២៖ ការវិភាគ SWOT សម្រាប់សមិទ្ធិលទ្ធភាពនៃអន្តរការីទិន្នន័យបើកចំហ

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ការចូលរួមដែលមានស្រាប់រវាងតួអង្គមិនមែនរដ្ឋ និងតួអង្គរដ្ឋ<br>• សមត្ថភាពមានស្រាប់ក្នុងចំណោមតួអង្គមិនមែនរដ្ឋ<br>• "ទំនុកចិត្ត" ដែលមានស្រាប់រវាងតួអង្គមិនមែនរដ្ឋមួយចំនួន  ទីភ្នាក់ងាររដ្ឋាភិបាល។ល។<br>• ការងារដែលកំពុងធ្វើឡើងដើម្បីលើកកម្ពស់ការចែករំលែកទិន្នន័យ | • ភាពមានកម្រិតនៃសមត្ថភាពបច្ចេកទេសនិងសមត្ថភាពហិរញ្ញវត្ថុក្នុងការបំពេញតួនាទីចាំបាច់ក្នុងនាមជាអន្តរការីទិន្នន័យបើកចំហ<br>• ទំនុកចិត្តរវាងតួអង្គមិនមែនរដ្ឋ និងរដ្ឋាភិបាល គឺនៅមានកម្រិត<br>• ភាពមានកម្រិតនៃការប្តេជ្ញាចិត្តរយៈពេលវែងរបស់ស្ថាប័នក្នុងការបំពេញតួនាទីនិងកសាងសមត្ថភាព |
| **ឱកាស** | **បញ្ហាប្រឈម** |
| • បរិយាកាសគោលនយោបាយអំណោយផលនិងផ្តល់ការលើកទឹកចិត្ត<br>• ផ្នែកជាក់លាក់សម្រាប់ការរួមចំណែកដោយតួអង្គមិនមែនរដ្ឋ ជាពិសេសការពិនិត្យតាមដាននិងវាយតម្លៃ និងការផ្តល់យោបល់ត្រឡប់<br>• ធន្ធៈរបស់ភាគីពាក់ព័ន្ធផ្សេងៗក្នុងការសហការគ្នា<br>• វឌ្ឍនភាពដែលសម្រេចបាននិងទិន្នន័យយ៉ាងច្រើនដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ<br>• អ្នកស្រាវជ្រាវវ័យក្មេងដែលមានសមត្ថភាពស្រូបយកចំណេះដឹងបច្ចេកទេសថ្មីៗ រួមទាំងបច្ចេកវិទ្យាឌីជីថល | • មិនសូវផ្តោតការយកចិត្តទុកដាក់លើហានិភ័យនៅពេលចែករំលែកទិន្នន័យនិងរបៀបកាត់បន្ថយហានិភ័យ<br>• ភាពមានកម្រិតនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍លើសមត្ថភាពដែលពាក់ព័ន្ធនឹងទិន្នន័យ ( ជាពិសេសសម្រាប់រយៈពេលវែង ) |

***ការប្តេជ្ញាចិត្ត និងការវិនិយោគរយៈពេលវែង ជាកត្តាសំខាន់សម្រាប់លទ្ធភាពនៃការបង្កើតឱ្យមានអន្តរការីទិន្នន័យដែលមានប្រសិទ្ធភាព និងនិរន្តរភាព។*** ផ្អែកតាមភាពចាំបាច់ និងតួនាទីរំពឹងទុករបស់អន្តរការីទិន្នន័យបើកចំហ និងការវិភាគ SWOT ខាងលើ គួរពិចារណាពីចំណុចសំខាន់ៗមួយចំនួននៅដំណាក់កាលរៀបចំ និងដំណាក់កាលអនុវត្តន៍ ដើម្បីឱ្យអន្តរការីទិន្នន័យអាចបំពេញ និងរក្សាតួនាទីរបស់ខ្លួន ក៏ដូចជាផ្តល់ការរួមចំណែកក្នុងរយៈពេលវែង។ អនុសាសន៍មានបង្ហាញក្នុងផ្នែកបន្ទាប់នៃរបាយការណ៍នេះ។ គួរកត់សម្គាល់ថា ការបំពេញការងារដោយអន្តរការីទិន្នន័យបើកចំហ ទាមទារការប្តេជ្ញាចិត្ត និងការវិនិយោគរយៈពេលវែង។

***គំនិតនៃការបង្កើតឱ្យមានសមាគមស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ ក៏អាចអនុវត្តបានផងដែរ ប៉ុន្តែគួរកំណត់យកជាចំណុចដៅ ដែលត្រូវសម្រេចបានក្នុងរយៈពេលមធ្យម។*** ក្នុងកិច្ចពិភាក្សាដែលនាំឱ្យមានការសិក្សានេះ មានការចោទសួរថាតើចាំបាច់ និងអាចបង្កើតឱ្យមាន និងដំណើរការសមាគមស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ឬទេ។ អ្នកផ្តល់ព័ត៌មានសំខាន់របស់យើងបានវាយតម្លៃខ្ពស់ចំពោះសំណួរនេះ ប៉ុន្តែបានលើកឡើងថា វេទិកានោះគួរបន្តធ្វើឡើងក្នុងរយៈពេលមធ្យម (លើកមកពិភាក្សាក្នុងផ្នែកបន្ទាប់)។

# ៥. អនុសាសន៍សម្រាប់ជំហានបន្ទាប់

ដើម្បីបង្កើតឱ្យមាន និងដំណើរការអន្តរការីទិន្នន័យប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ចាំបាច់ត្រូវមានយុទ្ធសាស្ត្រជារួមមួយ អមជាមួយនឹងខ្លឹមសារពិស្តារមួយចំនួន។ ផ្នែកស្តីពីអនុសាសន៍នេះគ្របដណ្តប់លើគំនិតសម្រាប់យុទ្ធសាស្ត្រជារួម ដែលភាគីពាក់ព័ន្ធផ្សេងៗអាចយកមកពិចារណាថាតើពួកគេគួរគាំទ្រដល់ការបង្កើតឱ្យមាន និងដំណើរការអន្តរការីទិន្នន័យបើកចំហឬទេ។

## ៥.១ ការពិចារណាជាយុទ្ធសាស្ត្រ

ការប្តេជ្ញាចិត្ត និងការរួមចំណែករយៈពេលវែងរបស់ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ ជាកត្តាចាំបាច់ក្នុងការធ្វើឱ្យអន្តរការីទិន្នន័យបើកចំហនៅកម្ពុជា លេចជារូបរាង។ ភាគីពាក់ព័ន្ធទាំងនោះ រួមមាន ១) អ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យបើកចំហ ២) ដៃគូអភិវឌ្ឍន៍ដែលផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសយ៉ាងហោចណាស់ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម និង ៣) ទីភ្នាក់ងាររដ្ឋាភិបាលដែលកិច្ចសហការរបស់ពួកគេដើរតួនាទីសំខាន់ក្នុងដំណើរការនេះទាំងមូល។

ផ្អែកតាមបទសម្ភាសន៍ អន្តរការីទិន្នន័យបើកចំហអាចចែកចេញជា ២ប្រភេទ៖

- **អន្តរការីទិន្នន័យបើកចំហដែលផ្តោតលើបញ្ហា៖** សំដៅលើស្ថាប័នដែលផ្តោតសំខាន់លើបញ្ហាជាក់លាក់ ដូចជា តម្លាភាពថវិកាសាធារណៈ អភិបាលកិច្ចមូលដ្ឋាន កិច្ចគាំពារសង្គម ការអប់រំ សុខភាព កសិកម្ម។ល។ ស្ថាប័នដែលគួរចាត់ចូលក្នុងប្រភេទនេះរួមមាន អង្គការមិនមែនរដ្ឋាភិបាលធំៗ ដែលខិតខំជួយដល់សមាជិករបស់ខ្លួន និងចូលរួមតស៊ូមតិឱ្យមានការផ្លាស់ប្តូរគោលនយោបាយក្នុងវិស័យអាទិភាពរបស់ខ្លួន។

- **អន្តរការីទិន្នន័យបើកចំហដែលផ្តោតសំខាន់លើការស្រាវជ្រាវ៖** សំដៅលើស្ថាប័នសិក្សាស្រាវជ្រាវ ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ និងសាកលវិទ្យាល័យដែលមិនផ្តោតសំខាន់លើការតស៊ូមតិក្នុងវិស័យជាក់លាក់ ប៉ុន្តែផ្តោតចម្បងលើការលើកកម្ពស់ការស្រាវជ្រាវ និងវិស័យស្រាវជ្រាវជារួម។ អ្នកទទួលផលពីស្ថាប័នទាំងនេះរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមអ្នកស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន។

ផ្អែកតាមបទសម្ភាសន៍ មានទីភ្នាក់ងាររដ្ឋាភិបាល ២ប្រភេទដែលត្រូវបានរំពឹងថានឹងអាចចូលរួមក្នុងដំណើរការនេះ៖

- **ក្រសួង/ទីភ្នាក់ងារសំខាន់ៗ** ដែលមានអាណត្តិផ្ទាល់ក្នុងអភិបាលកិច្ចទិន្នន័យសាធារណៈ ដូចជា វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង
- **ក្រសួង/ទីភ្នាក់ងារពាក់ព័ន្ធ** ដែលផលិត និងចែករំលែកទិន្នន័យស្តីពីវិស័យជាក់លាក់ (ឧ. ការអប់រំ សុខាភិបាល កសិកម្ម ការវិនិយោគ ពាណិជ្ជកម្ម)។

ផ្អែកតាមការវិភាគ SWOT ខាងលើ យុទ្ធសាស្ត្រជារួមនេះគួរ៖

- បង្កើនការចាប់យក និងការពង្រីកឱកាសឱ្យបានជាអតិបរមា
- កាត់បន្ថយផលជះអវិជ្ជមានឱ្យនៅតិចបំផុត និងកាត់បន្ថយហានិភ័យនាពេលបច្ចុប្បន្ន និងហានិភ័យដែលអាចកើតឡើង
- ផ្តោតលើការទាញប្រយោជន៍ និងការពង្រឹងចំណុចខ្លាំង និង
- ផ្តោតលើការកសាងសមត្ថភាពផ្ទៃក្នុង ដើម្បីលុបបំបាត់គម្លាត និងចំណុចខ្សោយ។

ផ្អែកតាមយុទ្ធសាស្ត្រដែលបានលើកឡើង មានផ្នែកជាច្រើនដែលអាចកំណត់យកជាអាទិភាពសម្រាប់ក្រុមតួអង្គនីមួយៗក្នុងចំណោមក្រុមតួអង្គទាំង៣ ខាងលើ (សូមមើលសេចក្តីសង្ខេបក្នុងតារាងខាងក្រោម)។

## តារាងទី៤៖ ចំណុចយុទ្ធសាស្ត្រដែលតួអង្គនីមួយៗត្រូវផ្តោតសំខាន់

| តួអង្គសំខាន់ៗ | ផ្នែក ឬកិច្ចការជាក់លាក់ដែលត្រូវផ្តោតសំខាន់ |
|---|---|
| ***អ្នកដែលអាចបំពេញតួនាទីជាអន្តរការី (សូមមើលខ្លឹមសារលម្អិតក្នុងផ្នែកបន្ទាប់)*** | - កំណត់ផ្នែកគោលនយោបាយដែលពួកគេគួរផ្តោតសំខាន់ ដើម្បីបញ្ជាក់ពីតួនាទី និងការរួមចំណែករបស់ពួកគេ<br>- បង្កើតផែនការរយៈពេលវែងដើម្បីអភិវឌ្ឍ និងធានានិរន្តរភាពក្នុងនាមជាអន្តរការីទិន្នន័យបើកចំហ<br>- បង្កើតទំនាក់ទំនង (គួរតែជាទំនាក់ទំនងផ្លូវការ) ជាមួយទីភ្នាក់ងាររដ្ឋដែលពាក់ព័ន្ធ និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីកសាងទំនុកចិត្ត និងកាត់បន្ថយហានិភ័យ<br>- ផ្តល់ការគាំទ្រជាក់លាក់ដល់ទីភ្នាក់ងាររដ្ឋាភិបាល ដែលអាចក្លាយជាដៃគូដើម្បីចែករំលែកបន្ទុកការងារមួយចំនួន ក្នុងគោលបំណងជំរុញការចែករំលែកទិន្នន័យ<br>- កំណត់រក និងទាក់ទងដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពល ដើម្បីទទួលបានការគាំទ្រ |
| ***ទីភ្នាក់ងាររដ្ឋាភិបាល*** | - បើកចំហលទ្ធភាពបង្កើតកិច្ចសហការផ្លូវការជាមួយតួអង្គមិនមែនរដ្ឋ ដែលមានបំណងចង់ធ្វើជាអន្តរការីទិន្នន័យបើកចំហ<br>- ផ្តល់ការគាំទ្រចាំបាច់ដល់អន្តរការីទិន្នន័យបើកចំហ ដូចជា ព័ត៌មានស្តីពីតម្រូវការគោលនយោបាយដែលពាក់ព័ន្ធ<br>- ធ្វើឱ្យការចែករំលែកទិន្នន័យកាន់តែមានភាពបើកចំហ និងផ្តល់ភាពងាយស្រួល ដោយអនុលោមតាមក្របខ័ណ្ឌគតិយុត្តិជាធរមាន និងការអនុវត្តជាអន្តរជាតិ<br>- ចែករំលែកការព្រួយបារម្ភ និងរិះរកដំណោះស្រាយរួមគ្នាជាមួយអន្តរការីទិន្នន័យបើកចំហស្តីពីវិធីល្អបំផុតក្នុងការកាត់បន្ថយហានិភ័យ នៅពេលចែករំលែកទិន្នន័យ<br>- អនុញ្ញាតឱ្យមានកិច្ចសន្ទនាជាបន្តបន្ទាប់ សម្រាប់ការរៀនសូត្រពីការអនុវត្តជាមួយអន្តរការីទិន្នន័យបើកចំហ |
| ***ដៃគូអភិវឌ្ឍន៍*** | - ផ្តោតអាទិភាពលើជំនួយមូលនិធិសម្រាប់គម្រោងទិន្នន័យ ជាពិសេសគម្រោងដែលអនុវត្តដោយអន្តរការីទិន្នន័យបើកចំហដែលជាតួអង្គមិនមែនរដ្ឋ<br>- ដើរតួនាទីជា "ស្ពាន" កសាងទំនុកចិត្ត និងលើកទឹកចិត្តឱ្យមានការចែករំលែកទិន្នន័យកាន់តែច្រើនរវាងតួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ<br>- ផ្សារភ្ជាប់តួអង្គដែលធ្វើការងារពាក់ព័ន្ធនឹងទិន្នន័យនៅកម្ពុជា (ទាំងរដ្ឋ និងមិនមែនរដ្ឋ) ទៅនឹងក្របខ័ណ្ឌតំបន់ និងក្របខ័ណ្ឌអន្តរជាតិ ដើម្បីពង្រីកការចែករំលែកចំណេះដឹង<br>- ធ្វើឱ្យមានភាពកាន់តែងាយស្រួលក្នុងការទទួលបានទិន្នន័យ ដែលប្រមូលបាន |

## ៥.២ អនុសាសន៍សម្រាប់អន្តរការីទិន្នន័យបើកចំហ

របាយការណ៍នេះលើកឡើងពីអនុសាសន៍ជាច្រើន សម្រាប់អ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យបើកចំហ ដូចជាពាក់ព័ន្ធនឹងរបៀបបង្កើត ដំណើរការ ធានានិរន្តរភាព និងពង្រីកសកម្មភាពរបស់អន្តរការីទិន្នន័យបើកចំហ ក្នុងរយៈពេលខ្លី និងរយៈពេលវែង។ អនុសាសន៍ខាងក្រោមគឺផ្អែកតាមបញ្ហា ឬកិច្ចការ អាចអនុវត្តបាន និងអាចបញ្ចូលក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ/ក្របខ័ណ្ឌលទ្ធភាពដែលកាន់តែមានសង្គតិភាព។

### តារាងទី៥៖ អនុសាសន៍មួយចំនួនសម្រាប់អ្នកដែលអាចបំពេញតួនាទីជាអន្តរការីទិន្នន័យបើកចំហ

| កិច្ចការជាក់លាក់ | អនុសាសន៍ |
|---|---|
| **១) ក្នុងដំណាក់កាលចាប់ផ្តើម** | |
| ***កំណត់គោលបំណងរយៈពេលវែង*** | - គោលបំណងរបស់អន្តរការីទិន្នន័យបើកចំហគួរឆ្លុះបញ្ចាំងពីតួនាទីរបស់ស្ថាប័ននេះ និងស៊ីសង្វាក់គ្នានឹងគោលនយោបាយរបស់រដ្ឋាភិបាល (ឧ. យុទ្ធសាស្ត្រជំរុញការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យ)។ |
| ***កំណត់ផ្នែកដែលអាចជំរុញការចូលរួមបាន*** | - ផ្នែកដែលអាចជំរុញការចូលរួមបាន គួរបន្សុីគ្នានឹងចំណុចផ្តោតសំខាន់ និងចំណុចខ្លាំងរបស់វា ។<br>- ផ្នែកមួយចំនួននៃការជំរុញការចូលរួម គួរផ្អែកតាមសក្តានុពលនៃការប្រើប្រាស់ទិន្នន័យកាន់តែប្រសើរ។ |
| ***កំណត់សំណួរគោលនយោបាយ (និងសូចនាករ)ដែលត្រូវផ្តោតសំខាន់*** | - ក្នុងផ្នែកទូលំទូលាយនៃការជំរុញការចូលរួម គួរពិចារណាល្អិតល្អន់នូវសំណួរគោលនយោបាយ ដើម្បីអាចកំណត់តម្រូវការទិន្នន័យចំគោលដៅ ។<br>- សំណួរគោលនយោបាយដែលពាក់ព័ន្ធអាចកំណត់ចេញពី ១) ឯកសារគោលនយោបាយតាមវិស័យ ដូចជា ផែនការយុទ្ធសាស្ត្រថវិកា ២) សូចនាករពាក់ព័ន្ធក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសូចនាករបន្ទាប់សន្សំ និង ៣) សំខាន់បំផុតគឺក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃសម្រាប់វិស័យនីមួយៗ។ |
| ***កំណត់តម្រូវការទិន្នន័យ និងទិន្នន័យដែលមាន*** | - គួរកំណត់សំណុំទិន្នន័យ និងចំណុចទិន្នន័យដែលត្រូវការចាំបាច់ដើម្បីបំពេញតម្រូវការគោលនយោបាយ និងតម្រូវការព័ត៌មានដែលបានជ្រើសរើស<br>- គួរគូសផែនទីបង្ហាញពីទិន្នន័យដែលមាន ប្រភព និងទម្រង់របស់វា និងកំណត់រកគម្លាតដែលនៅសេសសល់<br>- ពិនិត្យឡើងវិញលើក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃរបស់វិស័យពាក់ព័ន្ធ ដើម្បីឆ្លើយសំណួរទាំងនេះ |

| | |
|---|---|
| ***ស្វែងរកកិច្ចសហការផ្លូវការជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ*** | - ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធអាចរួមមានក្រសួង/ទីភ្នាក់ងារ ដែលទទួលបន្ទុកវិស័យជាក់លាក់ និង/ឬក្រសួង/ទីភ្នាក់ងារសំខាន់ៗដែលធ្វើការងារពាក់ព័ន្ធដោយផ្ទាល់នឹងបញ្ហាទិន្នន័យ។ ល្អបំផុតគឺ អន្តរការីទិន្នន័យគួរសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលទាំងពីរប្រភេទនេះ ដើម្បីធានាថា ទីភ្នាក់ងារទាំងនោះយល់ច្បាស់ពីបញ្ហាតាមវិស័យ និងបញ្ហាអភិបាលកិច្ចទិន្នន័យ។<br>- គួរបង្កើតកិច្ចសហការផ្លូវការ នៅដើមដំបូងបង្អស់នៃដំណើរការនេះ ដើម្បីធានាការទទួលយកជាផ្លូវការ ទំនុកចិត្ត និងភាពអាចជឿទុកចិត្តជាមួយអ្នកដែលអាចផ្តល់ជំនួយមូលនិធិបាន<br>- គួរបង្កើតទំនាក់ទំនងផ្លូវការ ដោយផ្អែកលើអនុស្សារណៈយោគយល់គ្នាដែលមានស្រាប់ ឬអនុស្សារណៈថ្មី។ អនុស្សារណៈនោះគួរលើកឡើងពីផ្នែកជាក់លាក់ដែលត្រូវផ្តោតសំខាន់ ទិន្នន័យដែលត្រូវប្រើប្រាស់ និងគោលការណ៍សំខាន់ៗ ដើម្បីកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធនឹងការចែករំលែកទិន្នន័យ។ |
| ***កំណត់តម្រូវការសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុ និងជំនួយមូលនិធិដែលអាចទទួលបាន*** | - គួរកំណត់រកជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុដែលត្រូវការចាំបាច់ និងរៀបចំសំណើមូលនិធិដែលអាចទទួលបាន<br>- ជំនួយមូលនិធិ អាចមានប្រភពពីទីភ្នាក់ងារម្ចាស់ជំនួយ ដែលកំពុងផ្តល់មូលនិធិដល់វិស័យទាំងនោះ ឬម្ចាស់ជំនួយផ្សេងទៀតនៅកម្រិតតំបន់ និងកម្រិតអន្តរជាតិ។ |

| ២) ក្នុងដំណាក់កាលអនុវត្តន៍ | |
|---|---|
| ***ទាញប្រយោជន៍ពីទិន្នន័យដែលត្រូវបានផ្ដល់ឱ្យប្រើប្រាស់ជាសាធារណៈ*** | - មុននឹងស្នើសុំទិន្នន័យបន្ថែមទៀតសម្រាប់ការចែករំលែក វាជាការសំខាន់ដែលត្រូវវិភាគ និងប្រើប្រាស់ទិន្នន័យដែលមានស្រាប់។<br>- អន្តរការីទិន្នន័យគួរធ្វើការ និងពិគ្រោះជាមួយដៃគូក្នុងជួររដ្ឋាភិបាល ដើម្បីកំណត់របៀបដែលពួកគេអាចទាញប្រយោជន៍ពីធនធាន និងថ្នាលឌីជីថលទាំងនោះ (ដូចជា CamStat)។ |
| ***តស៊ូមតិឱ្យមានការចែករំលែកជាសាធារណៈនូវទម្រង់ទិន្នន័យដែលកាន់តែផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់*** | - ក្នុងពេលបង្កើនការប្រើប្រាស់ទិន្នន័យដែលមានក្នុងទម្រង់ pdf អន្តរការីទិន្នន័យអាចតស៊ូមតិឱ្យមានការចែករំលែកសំណុំទិន្នន័យទាំងនោះក្នុងទម្រង់ Excel។ |
| ***ប្រើប្រាស់ថ្នាលឌីជីថលដើម្បីចែករំលែកទិន្នន័យដោយគិតគូរពីអ្នកប្រើប្រាស់*** | - ការចែករំលែកទិន្នន័យប្រកបដោយប្រសិទ្ធភាព ត្រូវធ្វើឡើងតាមប្រព័ន្ធអ៊ីនធឺណិត និងក្នុងទម្រង់ដែលផ្ដល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ ដែលទាមទារការវិនិយោគដើម្បីអភិវឌ្ឍ និងធានានិរន្តរភាព។ |
| ***វិនិយោគលើកិច្ចខិតខំប្រឹងប្រែងចាំបាច់ដើម្បីប្រែក្លាយសំណុំទិន្នន័យសំខាន់ៗដែលមានស្រាប់ពីទម្រង់ PDF ទៅជាទម្រង់ Excel*** | - ក្នុងពេលតស៊ូមតិឱ្យរដ្ឋាភិបាលបញ្ចេញទិន្នន័យក្នុងទម្រង់ Excel អន្តរការីទិន្នន័យគួរមានធនធានវិនិយោគធនធានមួយចំនួន (ឧ. ការជួលបុគ្គលិក និងអ្នកហាត់ការកាន់តែច្រើន ការអភិវឌ្ឍមូលដ្ឋានទិន្នន័យ ឬគេហទំព័រ) ដើម្បីបម្លែងសំណុំទិន្នន័យដែលមានក្នុងទម្រង់ PDF ទៅជាទម្រង់ Excel និងផ្ដល់ឱ្យប្រើប្រាស់នៅក្នុងគេហទំព័រ។ |
| ***បង្កើតផ្ទាំងបង្ហាញព័ត៌មានដើម្បី "រ៉ាយរ៉ាប់" ពីទិន្នន័យទាំងនោះ*** | - ការមានផ្ទាំងបង្ហាញព័ត៌មានក្នុងគេហទំព័រ ជាវិធីល្អមួយក្នុងការ ១) បង្ហាញថាតើហេតុអ្វីការចែករំលែកទិន្នន័យនឹងជួយជាប្រយោជន៍ និង ២) បង្ហាញរឿងរ៉ាវសាមញ្ញៗពីទិន្នន័យដែលប្រមូលបាន។ ចំណុចនេះអាចបង្កើតជា "ផលជះនៃការបង្ហាញជាវិជ្ជមាន" សម្រាប់អ្នកចែករំលែកទិន្នន័យ និងអ្នកប្រើប្រាស់ទិន្នន័យ។ |
| ***ពិចារណាពីលក្ខខណ្ឌមួយចំនួនសម្រាប់ការប្រើប្រាស់ទិន្នន័យពីគេហទំព័រ*** | - ក្នុងពេលផ្សព្វផ្សាយទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណិត គួរភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួន ដើម្បីការពារស្ថាប័នដែលបង្ហោះទិន្នន័យទាំងនោះ ពីហានិភ័យដែលអាចកើតឡើង។<br>- អន្តរការីទិន្នន័យ គួរយោងតាមបទបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនៅកម្ពុជា (ត្រូវកំណត់) ឬការអនុវត្តរបស់ស្ថាប័នអន្តរជាតិ (ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី) ដើម្បីបង្កើតលក្ខខណ្ឌទាំងនោះ[29] ។ |

[29] សម្រាប់ឧទាហរណ៍នៃលក្ខខណ្ឌរបស់ ADB សម្រាប់ការប្រើប្រាស់សំណុំទិន្នន័យ ដែលត្រូវបានចែករំលែកក្នុងគេហទំព័ររបស់ ADB សូមចូលទៅកាន់៖ https://data.adb.org/terms-use-data

| | |
|---|---|
| *ជំរុញការចូលរួមរបស់យុវជនក្នុងដំណើរការនេះ (ជាពិសេសក្នុងផ្នែកដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល)* | - អន្តរការីទិន្នន័យគួរជ្រើសរើសយុវជន (ពេញម៉ោង ឬក្រៅម៉ោង អ្នកហាត់ការ ឬអ្នកស្ម័គ្រចិត្ត) ឱ្យជួយដល់ការងារដែលពាក់ព័ន្ធនឹងទិន្នន័យ ដូចជាការបញ្ចូលទិន្នន័យ អង្កេតអនឡាញ ការចែករំលែកទិន្នន័យ ការអភិវឌ្ឍគេហទំព័រ។ល។ |
| *ផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំ និងការបណ្តុះបណ្តាលស្តីពីភាពអាចរកបានទិន្នន័យ ការវិភាគទិន្នន័យ និងការប៉ាន់ប្រមាណទិន្នន័យ* | - អន្តរការីទិន្នន័យគួរចាត់ទុកថា ខ្លួនមានតួនាទីផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំ និងការបណ្តុះបណ្តាលស្តីពីភាពអាចរកបានទិន្នន័យ ការវិភាគទិន្នន័យ និងការប៉ាន់ប្រមាណទិន្នន័យ ទៅតាមធនធានរបស់ខ្លួន។ |
| *ប្រមូលយកយោបល់ត្រឡប់ជាប្រចាំពីអ្នកប្រើប្រាស់ទិន្នន័យ* | - បង្កើតយន្តការដាក់លាក់ដើម្បីទទួលបានយោបល់ត្រឡប់ជាប្រចាំពីអ្នកប្រើប្រាស់ទិន្នន័យ មិនថាពួកគេជាសមាជិករបស់អន្តរការីទិន្នន័យបើកចំហ (ឬអង្គការមិនមែនរដ្ឋាភិបាលជាសមាជិក) ឬជាអ្នកស្រាវជ្រាវទូទៅនោះទេ។ |
| *ប្រាស្រ័យទាក់ទងជាប្រចាំជាមួយទីភ្នាក់ងាររដ្ឋាភិបាលដើម្បីផ្តល់ធាតុចូល និងយោបល់ត្រឡប់* | - សម្របសម្រួលការប្រាស្រ័យទាក់ទងជាប្រចាំ ជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីបង្កើនទំនុកចិត្ត និងការយោគយល់គ្នាទៅវិញទៅមក ជាពិសេសពាក់ព័ន្ធនឹងហានិភ័យ និងសារៈប្រយោជន៍នៃការចែករំលែកទិន្នន័យ |

| ៣) ដំណាក់កាលធានានិរន្តរភាព និងពង្រីកបន្ថែម | |
|---|---|
| ***បង្ហាញប្រសិទ្ធភាពតាមរយៈការរៀនសូត្រពីការអនុវត្ត*** | - គួរប្រើប្រាស់អភិក្រមជាក់ស្តែង ប៉ុន្តែមានប្រសិទ្ធភាព ពោលគឺការរៀនសូត្រពីការអនុវត្ត។ អភិក្រមនេះអាចស្តែងឡើងតាមរយៈការផ្តល់ធាតុចេញ ការផ្តល់យោបល់ត្រឡប់ និងការកែសម្រួលជាប្រចាំក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ។<br>- លទ្ធភាពនៃការធានានិរន្តរភាព និងការពង្រីកការងាររបស់អន្តរការីទិន្នន័យបើកចំហ ផ្អែកជាចម្បងលើសមត្ថភាពរបស់ស្ថាប័នទាំងនេះក្នុងការបង្កើត "ផលជះនៃការបង្ហាញ" ដើម្បីធ្វើយ៉ាងណាឱ្យទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ មើលឃើញគុណតម្លៃនៃតួនាទី និងការរួមចំណែករបស់អន្តរការីទិន្នន័យបើកចំហ។ |
| ***ពិចារណាសហការជាមួយតួអង្គមិនមែនរដ្ឋផ្សេងទៀត (ដូចជាការបង្កើតសមាគមស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់)*** | - នៅពេលបានកសាងទំនុកចិត្ត ហើយអន្តរការីទិន្នន័យនីមួយៗបានបញ្ជាក់ពីភាពអាចជឿជាក់បានរបស់ខ្លួន គេអាចពិចារណាសហការគ្នា ដោយមានការកំណត់ផ្នែកជាក់លាក់នៃការរួមចំណែក និងគណនេយ្យភាព។<br>- ប្រសិនបើយល់ថាមានប្រយោជន៍ អាចបង្កើតសមាគមមួយដែលចូលរួមដោយស្ថាប័នស្រាវជ្រាវ និងអន្តរការីទិន្នន័យជាច្រើន។ |
| ***ពិចារណាបំពេញតួនាទីកម្រិតខ្ពស់ជាងមុនក្នុងនាមជាអន្តរការីទិន្នន័យ*** | - នៅពេលមានសមត្ថភាពកាន់តែខ្លាំង អន្តរការីទិន្នន័យអាចផ្តោតលើសពី "ទិន្នន័យបើកចំហរបស់រដ្ឋាភិបាល" និងងាកទៅរក "ទិន្នន័យ" ទូទៅ។ ក្នុងករណីនេះ អន្តរការីទិន្នន័យអាចពិចារណាបំពេញតួនាទីកាន់តែច្រើន ដូចជា បរធនបាលកិច្ចទិន្នន័យ ការផ្លាស់ប្តូរទិន្នន័យ ប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួន ថ្នាលទិន្នន័យឧស្សាហកម្ម អ្នកគ្រប់គ្រងទិន្នន័យ កិច្ចសហប្រតិបត្តិការទិន្នន័យ និងភាគីទីបីដែលទទួលបានទំនុកចិត្ត[30] ។ |

[30] ( CDEI, 2021 )

# ឯកសារយោង


- CDEI. (2021). *Unlocking the value of data: Exploring the role of data intermediaries. London.*
- Francois, S., Canares, M., Chattapadhay, S., & Andrason, A. (2016). *Open data intermediaries in developing countries. The Journal of Community Informatics, 1721-4441.*
- IDB. (2018). *Toward an open data demand assessment and segmentation methodology. Washington DC.*
- Janssen Heleen, Singh Jatinder. (2022). *Data intermediary. Internet Policy Review.*
- NIS. (2021). *Draft Data User Engagement Strategy. Phnom Penh.*
- NIS. (Upcoming). *User Engagement Strategy (Draft). Phnom Penh.*
- ODI. (2022). *Assessing risk when sharing data: A guide. London.*
- OECD. (2013). *Open government data: Towards empirical analysis of open government data initiatives. OECD.*
- RGC. (2018). *National Strategy for the Development of Statistics (2019-2023).*
- RGC. (2021). *Cambodia Digital Economy and Society Policy Framework 2021-2035. Phnom Penh.*
- RGC. (2021). *Strategic Framework and Program for Cambodia's Economic Recovery (2021-2023).*
- RGC. (2022). *Digital Government Policy. Phnom Penh.*
- The Foundation. (2022). *A Diagnostic Study on the Policy Process and Use of Data: The Case of Cambodia and Insights from ASEAN, Phnom Penh. Phnom Penh.*
- UNDESA. (2020). *E-Government survye for 2020. New York.*
- UNDESA. (2022). *E-Government survey 2022: The future of digital government. New York.*
- World Bank. (2021). *World Development Report 2021: Data for Better Lives. Washington, DC.*
- WTO. (2022). *Trade impacts of LDC graduation - Cambodia.*

កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា គឺជាកម្មវិធីមួយមានរយៈពេលបួនឆ្នាំ ដែលផ្តួចផ្តើមឡើងដោយអង្គការមូលនិធិអាស៊ី ក្នុងគោលបំណងរួមចំណែកពង្រឹងសមត្ថភាពស្ថាប័នស្រាវជ្រាវ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាទិន្នន័យគាំទ្រដល់ការវិភាគ និងការពិភាក្សាអំពីគោលនយោបាយសាធារណៈនៅកម្ពុជា ក្រោមការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។


## អង្គការមូលនិធិអាស៊ី

ផ្ទះលេខ៥៩ ផ្លូវ២៤២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ponlokchomnes@asiafoundation.org
+៨៥៥ (០)២៣ ២១០ ៤៣១
https://policypulse.org/


Australian Aid

ពន្លក ចំណេះ

The Asia Foundation